សាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Economiques

Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# បណ្តឹងទាស់ក្នុងនីតិវិធីរដ្ឋប្បវេណី

ស្រាវជ្រាវចាប់ពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨

តាក់តែងឡើងដោយ

និស្សិតឈ្មោះ **ឡាយ អ៊ីហុង**

**គង់ ច័ន្ទវល័ក្ខ**

សាស្ត្រាចារ្យណែនាំ

លោក **គង់ សុភ័ក្ត្រ**

ថ្នាក់បរិញ្ញាបត្រ នីតិសាស្ត្រ

ជំនាន់ទី ១៨

ឆ្នាំចូលសិក្សា ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទ **ឡាយ អ៊ីហុង** និង នាងខ្ញុំ **គង់ ច័ន្ទថលក័ក្ខ** ជានិស្សិតថ្នាក់បរិញ្ញាបត្រផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី ១៨ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០១៤ - ២០១៨ សូមសម្តែងនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ និង កតញ្ញូតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ៖

**លោកឪពុក អ្នកម្តាយ** ដ៏មានគុណមិនអាចកាត់ថ្លៃបាន ដែលបានផ្តល់កំណើត និង ចិញ្ចឹមបីបាច់ថែរក្សាកូន ដោយចិត្តសណ្តោសប្រណី អប់រំប្រៀនប្រដៅ ប្រកបដោយ ព្រហ្មវិហារធម៌ គុណធម៌ សប្បុរសធម៌ ព្រមទាំងឱ្យកូនបានរៀនសូត្រតាំងពីបឋមសិក្សារហូតដល់ ឧត្តមសិក្សា ។ លើសពីនេះទៅទៀត លោកទាំងពីរ បានជួយឧបត្ថម្ភគាំទ្រផ្នែកថវិកា លើកទឹកចិត្ត ជម្រុញស្មារតី ដើម្បីជាមធ្យោបាយឱ្យយើងខ្ញុំបានទទួលនូវចំណេះដឹង រហូតបានបញ្ចប់ថ្នាក់បរិញ្ញាបត្រនេះ ។

**ឯកឧត្តមបណ្ឌិត លុយ ចណ្ណា សាកលវិទ្យាធិការ និងសាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំង លោក លោកស្រី អ្នកនាងកញ្ញា ជាសាស្ត្រាចារ្យ** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានប្រឹងប្រែងបង្ហាត់បង្រៀន និង ផ្តល់បទពិសោធន៍ល្អៗ ប្រកបដោយសមត្ថភាពខ្ពង់ខ្ពស់ ដើម្បីជាមូលដ្ឋានដ៏រឹងមាំសម្រាប់ប្រកបវិជ្ជាជីវៈឱ្យកាន់តែប្រសើរ និង ចូលរួមពង្រឹង វិស័យច្បាប់នៅកម្ពុជាឱ្យកាន់តែរីកចម្រើនប្រកបទៅដោយចីរភាព ។

លោកគ្រូ **គង់ សុភ័ក្រ** ដែលបានខិតខំយកចិត្តទុកដាក់ លះបង់នូវពេលវេលាដ៏មានតម្លៃក្នុងការជួយណែនាំ កែសម្រួលខ្លឹមសារ អក្ខរាវិរុទ្ធដែលខ្វះខាត និង បានផ្តល់នូវជាគំនិតល្អៗ ដើម្បីឱ្យសារណារបស់យើងខ្ញុំទទួលបាននូវលទ្ធផលមួយដ៏ល្អប្រសើរ ។

សិស្សច្បង មិត្តរួមជំនាន់ មិត្តរួមថ្នាក់ ដែលបានចូលរួមផ្តល់នូវយោបល់ល្អៗ ក្នុងការសិក្សាស្រាវជ្រាវ និង សរសេរសារណានេះឱ្យលេចចេញជារូបរាងឡើងបានយ៉ាងរលូន ។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់ សូមប្រសិទ្ធិពរជ័យជូនដល់ **លោកអ្នកមានគុណទាំងពីរ ឯកឧត្តមបណ្ឌិតសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង ព្រមទាំង លោក លោកស្រី អ្នកនាងកញ្ញា ជាសាស្ត្រាចារ្យ សិស្សច្បង មិត្តរួមជំនាន់ មិត្តរួមថ្នាក់** ទាំងអស់ឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

ក្រោយពីបានសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ នៅ**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច** អស់រយៈពេល៤ឆ្នាំកន្លងមកនេះ យើងខ្ញុំបានចាប់អារម្មណ៍យ៉ាងខ្លាំងលើមុខវិជ្ជាដែលទាក់ទងនឹងផ្នែករដ្ឋប្បវេណី ។ យើងខ្ញុំរំពឹងថានៅពេលបញ្ចប់ថ្នាក់បរិញ្ញាបត្រ យើងខ្ញុំនឹងជ្រើសរើសយកប្រធានបទមួយដែលទាក់ទងនឹងនីតិវិធីរដ្ឋប្បវេណីមកសរសេរជាអត្ថបទសារណា ។ ជាលទ្ធផលនៅឆ្នាំទី ៤ ឆមាសទី១ ឈ្មោះរបស់យើងខ្ញុំទាំងពីរនាក់ត្រូវបានសាលាតម្រូវឱ្យសរសេរសារណា ដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ ។ ខណៈនោះយើងខ្ញុំក៏បានស្នើសុំយោបល់ពី **លោកគ្រូ គង់ សុភ័ក្រ្ត** អំពីប្រធានបទមួយស្ដីពី " **បណ្ដឹងទាស់ក្នុងនីតិវិធីរដ្ឋប្បវេណី** " ។ ក្រោយពីលោកគ្រូបានសាកសួរយើងខ្ញុំខ្លះៗអំពីប្រធានបទនេះហើយ លោកក៏បានឯកភាព និង បានណែនាំយើងខ្ញុំដើម្បីសរសេរសារណាមួយនេះ ។

ឆ្លើយតបទៅនឹងសារណា ដែលត្រូវសរសេរដើម្បីបញ្ចប់ថ្នាក់បរិញ្ញាបត្រ និង ដើម្បីស្វែងយល់ឱ្យកាន់តែស៊ីជម្រៅ យើងខ្ញុំបានត្រៀមទាំងកម្លាំងកាយ និង កម្លាំងចិត្តដើម្បីបំពេញនូវកិច្ចការនេះឱ្យបានល្អទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ យើងខ្ញុំបានស្រាវជ្រាវ និង រៀបចំនូវលិខិតបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធនឹងប្រធានបទនៃសារណានេះ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏ស្នាដៃនេះមិនមែនជាស្នាដៃចុងក្រោយ និង ល្អឥតខ្ចោះគ្មានកន្លែងកែតម្រូវនោះទេ ការស្រាវជ្រាវនេះ គឺគ្រាន់តែជាការចូលរួមក្នុងការស្រាវជ្រាវ ក្នុងគោលបំណងចែករំលែកនូវចំណេះដឹងដល់និស្សិតជំនាន់ក្រោយ ក៏ដូចជាប្រជាពលរដ្ឋឱ្យបានយល់ដឹងបន្ថែម និង ធ្វើការការបកស្រាយបន្ថែមនូវចំណុចមួយចំនួនដែលពាក់ព័ន្ធទៅនឹងបណ្ដឹងទាស់ដែលបានកំណត់ក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ។ ដូច្នេះ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថាលោកអ្នកអានទាំងអស់គ្នានឹងអធ្យាស្រ័យនូវរាល់ចំណុចខ្វះខាត ដែលមាននៅក្នុងសារណានេះ ។ ជាមួយគ្នានេះ យើងខ្ញុំក៏បានភ្ជាប់ជាមួយនូវឯកសារយោងមួយចំនួនផងដែរ ដើម្បីជាមូលដ្ឋានគ្រឹះនៃការស្រាវជ្រាវ និង ដើម្បីបញ្ជាក់អំពីចំណុចត្រង់ណា ដែលលោកអ្នកអានមានមន្ទិលសង្ស័យ ។ ដូច្នេះបើមានចំណុចត្រង់ណាមិនច្បាស់ ឬ មិនសមហេតុផល សូមមេត្តាជួយពិនិត្យបន្ថែមតាមរយៈឯកសារយោងដែលយើងខ្ញុំបានដាក់ជូននៅទំព័រខាងក្រោយ ។

ជាចុងបញ្ចប់ប្រសិនបើមានកង្វះខាត ឬ កំហុសឆ្គងត្រង់ចំណុចណាមួយ យើងខ្ញុំសូមទទួលយកនូវការរិះគន់ពីសំណាក់ លោក-លោកស្រីសាស្ត្រាចារ្យ សិស្ស និស្សិត គ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីស្ថាបនាក្នុងការអភិវឌ្ឍសមត្ថភាព ដោយក្តីគោរព និង ក្តីរាប់អានយ៉ាងកក់ក្ដៅបំផុត ដើម្បីឱ្យសារណាមួយនេះឱ្យមានភាពកាន់តែល្អប្រសើរ ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ..... ១

## ជំពូកទី១

## សញ្ញាណទូទៅនៃបណ្តឹងទាស់

**១.១. លក្ខខណ្ឌដែលអាចធ្វើបណ្តឹងទាស់** ..... ៤

១.១.១ សាលក្រមដែលអាចធ្វើបណ្តឹងទាស់ ..... ៦

១.១.២. អំឡុងពេលដែលអាចធ្វើបណ្តឹងទាស់បាន ..... ៧

**១.២. សិទ្ធិក្នុងការធ្វើបណ្តឹងទាស់** ..... ៨

១.២.១. សមត្ថភាពភាគីក្នុងការធ្វើបណ្តឹងទាស់ ..... ៨

១.២.២. អានុភាពតាមផ្លូវច្បាប់នៃសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់ ..... ១២

១.២.៣. ការលះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ..... ១៤

**១.៣. របៀបធ្វើបណ្តឹងទាស់ និង អានុភាពនៃបណ្តឹងទាស់** ..... ១៤

១.៣.១. របៀបធ្វើបណ្តឹងទាស់ ..... ១៤

១.៣.២. អានុភាពនៃបណ្តឹងទាស់ ..... ១៥

## ជំពូកទី២

## ចំណាត់ការលើនីតិវិធីលើបណ្តឹងទាស់

**២.១. ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង** ..... ១៦

២.១.១. សមត្ថកិច្ចរបស់តុលាការ ..... ១៦

២.១.២. អានុភាពនៃពាក្យបណ្តឹងទាស់ ..... ១៧

**២.២. ការដកពាក្យបណ្តឹង និង ការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់** ១៨

២.២.១. ការដកពាក្យបណ្តឹងទាស់ ........ ១៨

២.២.២. ការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់ ........ ១៩

២.២.៣. ការកោះហៅគូភាគី ........ ២០

**២.៣. ការសម្រេចសេចក្តីលើបណ្តឹងទាស់** ........ ២៤

២.៣.១. ការស្រាវជ្រាវលើមូលហេតុនៃបណ្តឹងទាស់ដោយឆន្ទានុសិទ្ធិរបស់តុលាការ ........ ២៤

២.៣.២. សាលក្រមសម្រេចលើបណ្តឹងទាស់ ........ ២៥

**២.៤. សាលក្រមកំបាំងមុខលើកទី២** ........ ២៥

២.៣.១. មូលហេតុដែលមិនអាចចេញនូវសាលក្រមកំបាំងមុខលើកទី២ ........ ២៦

២.៣.២. ការហាមឃាត់ធ្វើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខលើកទី២ ........ ២៩

**សេចក្តីសន្និដ្ឋាន** ........ ៣០

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដែលព្រះមហាក្សត្របានឡាយព្រះហស្ថលេខាដាក់ឱ្យប្រើប្រាស់កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ គឺជាច្បាប់កំពូលមួយរបស់រដ្ឋ ដោយមានបញ្ញត្តិអំពីស្ថាប័នធំៗចំនួន០៣ (បី) រួមមាន៖ ស្ថាប័ននីតិប្បញ្ញត្តិ ស្ថាប័ននីតិប្រតិបត្តិ និង ស្ថាប័នតុលាការ ហើយស្ថាប័នទាំងបីនេះមានតួនាទី និង ភារកិច្ចផ្សេងៗគ្នា ដើម្បីធានាមិនឱ្យមានការរំលោភអំណាចទៅវិញទៅមក ។ ក្នុងចំណោមស្ថាប័នដែលរៀបរាប់ខាងលើស្ថាប័នតុលាការ មានតួនាទីក្នុងការអនុវត្តច្បាប់ និង ធ្វើការដាក់វិន័យ ចំពោះជនទាំងឡាយណា ដែលល្មើសនឹងច្បាប់តាមរយៈការសម្រេចសេចក្តីដោយសំអាងទៅលើបទប្បញ្ញត្តិច្បាប់ដែលនូវជាធរមាន ។ ទន្ទឹមនឹងការអនុវត្តច្បាប់ និង ការដាក់វិន័យ ចំពោះជនដែលល្មើសនឹងច្បាប់ ក៏ត្រូវតែមានការធានា និង ការពារដល់សិទ្ធិ និង សេចក្តីថ្លៃថ្នូររបស់មនុស្សមុននឹងសន្មត់ថាជននោះត្រូវទទួលវិន័យ លុះត្រាតែត្រូវជននោះត្រូវបាន តុលាការចេញសាលក្រម ឬ សាលដីកាអំពីកំហុសដែលជននោះបានប្រព្រឹត្ត ឬ កំហុសដោយសារជននោះមិនបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួន ។ ប៉ុន្តែមុននឹងឈានដល់ការចេញសេចក្តីសម្រេច តុលាការត្រូវគោរពនូវគោលការណ៍ចំពោះមុខ ដែលមានបញ្ញត្តិនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៦ ដូច្នេះតម្រូវឱ្យមានវត្តមានភាគីនៅគ្រប់ដំណាក់កាលនៃនីតិវិធី ។ ប៉ុន្តែប្រសិនបើភាគីអវត្តមានដោយមិនមានមូលហេតុច្បាស់លាស់ តុលាការអាចចេញនូវសាលក្រមកំបាំងមុខភាគីនោះបាន ។ បន្ថែមលើសពីនេះ តុលាការបានទុកសិទ្ធិឱ្យភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខមានសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខបាន ។

ស្របពេលដែលច្បាប់បានបើកសិទ្ធិឱ្យតុលាការចេញសាលក្រមកំបាំងមុខ ច្បាប់ក៏បានទុកសិទ្ធិឱ្យភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខនោះ មានសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខផងដែរ ។ ដោយឃើញនូវចំណុចទាំងអស់នេះហើយ ទើបយើងខ្ញុំសម្រេចជ្រើសរើសយក បណ្តឹងទាស់ក្នុងនីតិវិធីរដ្ឋប្បវេណីមកធ្វើជាប្រធានបទសារណាដើម្បីបកស្រាយក្នុងគោលបំណង បង្ហាញឱ្យឃើញពីសារៈសំខាន់នៃបណ្តឹងទាស់ ដែលអាចធ្វើឡើងចំពោះសាលក្រមកំបាំងមុខ ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដើម្បីធ្វើការសិក្សាឱ្យមានភាពស៊ីជម្រៅ និង មានភាពកាន់តែច្បាស់លាស់ទៅលើប្រធានបទសារណាខាងលើ យើងខ្ញុំបានលើកឡើងនូវចំណោទបញ្ហាគតិយុត្តមួយចំនួន យកមកធ្វើការ

ដោះស្រាយ ដែលចំណោទបញ្ហាគតិយុត្តទាំងនោះរួមមាន ៖ បន្ទាប់ពីតុលាការបានចេញនូវសាលក្រមកំបាំងមុខរួចមក ភាគីដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ មានសិទ្ធិ កាតព្វកិច្ច និង ជម្រើស អ្វីខ្លះ ចំពោះសាលក្រមកំបាំងមុខនោះ ប្រសិនបើខ្លួនមិនយល់ស្របទៅលើសាលក្រមនោះ ? តើតុលាការមានចំណាត់ការបែបណាចំពោះបណ្តឹងទាស់ ដែលភាគីអវត្តមានបានធ្វើឡើង ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងក្នុងការកំណត់យកប្រធានបទស្តីពី "បណ្តឹងទាស់ក្នុងនីតិវិធីរដ្ឋប្បវេណី" យកមកសរសេរជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ គឺដើម្បីសិក្សាឱ្យកាន់តែយល់ច្បាស់ពី សិទ្ធិ កាតព្វកិច្ច និង ជម្រើសរបស់ភាគីដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ និង ចំណាត់ការរបស់ស្ថាប័នតុលាការ ទៅលើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។ ការសិក្សាស្រាវជ្រាវធ្វើឡើងដើម្បីជាប្រយោជន៍ នៅក្នុងការយល់ដឹង និង ដើម្បីចែកជាពុទ្ធិទៅដល់បងប្អូនមិត្តនិស្សិតនៅក្នុងការសិក្សារៀនសូត្រ ស្វែងយល់បន្ថែម ពីបណ្តឹងទាស់ក្នុងនីតិវិធីរដ្ឋប្បវេណី ។

## ៤. ទំហំ និង ដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទនៃការសិក្សាស្រាវជ្រាវនេះ យើងខ្ញុំបានកំណត់ធ្វើការសិក្សាស្រាវជ្រាវ ចាប់ពីដំណាក់កាលនៃការដាក់ពាក្យបណ្តឹងទាស់ រហូតដល់ការវិនិច្ឆ័យ និង សម្រេចសេចក្តីលើបណ្តឹងទាស់ ។ ជាងនេះទៅទៀតវង្វង់នៃការស្រាវជ្រាវ ចំពោះមាត្រាដែលបានបញ្ញត្តិក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦ តែប៉ុណ្ណោះ ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចំពោះសារៈសំខាន់នៃការសិក្សាស្រាវជ្រាវនេះ នឹងចូលរួមជាផ្នែកមួយដ៏សំខាន់សម្រាប់ការសិក្សាស្រាវជ្រាវ ពង្រីកនូវចំណេះដឹងបន្ថែម របស់បងប្អូនមិត្តនិស្សិត ក៏ដូចជាចូលរួមជាវិភាគទាននៅក្នុងការចែករំលែកជូនទៅដល់ បងប្អូនប្រជាពលរដ្ឋ នៅក្នុងការយល់ដឹងបន្ថែមទៀតពាក់ព័ន្ធទៅនឹង បណ្តឹងទាស់ក្នុងនីតិវិធីរដ្ឋប្បវេណីនេះ ។

## ៦. វិធីសាស្ត្រក្នុងការស្រាវជ្រាវ

ទិន្នន័យដែលប្រមូលបាន គឺយកមកវិភាគតាមរយៈពិពណ៌នាបែបគុណភាព ដោយប្រើទិន្នន័យទីមួយ ( Primary Data ) និង ទិន្នន័យទីពីរ ( Secondary Data ) បូករួមបញ្ចូលគ្នា ដើម្បីបានសមិទ្ធផលនៃស្នាដៃនេះឡើង ។

- ទិន្នន័យទីមួយ ជាប្រភេទទិន្នន័យផ្ទាល់ ( Primary Data ) ដោយបានសាកសួរសំណួរមួយចំនួនទៅកាន់មន្ត្រីដែលបានធ្វើការនៅសាលាដំបូង លោកមេធាវី និង សាស្ត្រាចារ្យណែនាំ ។

- ទិន្នន័យទីពីរ ( Secondary Data ) ដែលបានមកពីការដកស្រង់នូវខ្លឹមសារសំខាន់ៗ និង ចាំបាច់នានា ដែលប្រមូលបានពីលិខិតបទដ្ឋានគតិយុត្តជាតិ ដែលមានជាធរមាន សៀវភៅ របាយការណ៍ នៅតាមបណ្ណាល័យនានានៅក្នុងរាជធានីភ្នំពេញ ព្រមទាំងឯកសារពាក់ព័ន្ធមួយចំនួនទៀត ដែលយើងខ្ញុំបានដាក់នៅក្នុងឧបសម្ព័ន្ធ និង ឯកសារយោងខ្លះៗ ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហាគតិយុត្តខាងលើ និង ដើម្បីធ្វើការសិក្សាឱ្យបានគ្រប់ជ្រុងជ្រោយ និង កាន់តែមានភាពស៊ីជម្រៅ ហើយច្បាស់លាស់ទៀតនោះ យើងបានធ្វើការបែងចែកជា០២ (ពីរ) ជំពូកធំៗ ដែលក្នុងនោះរួមមាន៖

- សេចក្តីផ្តើម ៖ ផ្នែកនេះចង់បង្ហាញឱ្យឃើញអំពី លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ និង រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ។
- ជំពូកទី១ សញ្ញាណទូទៅនៃបណ្តឹងទាស់ ៖ នៅក្នុងជំពូកនេះ នឹងបង្ហាញលោកអ្នកឱ្យបានយល់ដឹងអំពី ល័ក្ខខ័ណ្ឌដែលអាចធ្វើបណ្តឹងទាស់ (១.១) សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ (១.២) របៀបធ្វើបណ្តឹងទាស់ និង អានុភាពនៃបណ្តឹងទាស់ (១.៣) ។
- ជំពូកទី២ ចំណាត់ការលើនីតិវិធីនៃបណ្តឹងទាស់ ៖ នៅក្នុងជំពូកនេះ នឹងបង្ហាញឱ្យលោកអ្នកយល់ដឹងអំពី ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង (២.១) ការដកពាក្យបណ្តឹង និង សម្រេចសេចក្តីលើបណ្តឹងទាស់ (២.២) និង សាលក្រមកំបាំងមុខលើកទី២ (២.៣) ។
- សេចក្តីសន្និដ្ឋាន ៖ យើងខ្ញុំធ្វើការលើកឡើងនូវសេចក្តីសន្និដ្ឋានជារួម នៅក្នុងប្រធានបទនេះ។

# ជំពូកទី១. សញ្ញាណទូទៅនៃបណ្តឹងទាស់

ដោយសារក្រមនីតិវិធីរដ្ឋប្បវេណី គោរពតាមគោលការណ៍ចំពោះមុខ ដែលតម្រូវឱ្យមានវត្តមានភាគីតាមកាលបរិច្ឆេទ ដែលបានកំណត់ដោយតុលាការ ដើម្បីឱ្យភាគីធ្វើនូវសេចក្តីថ្លែងការណ៍អះអាងអំពីអង្គហេតុ ដាក់មធ្យោបាយតទល់ និង ធ្វើសកម្មភាពបណ្តឹងនៅគ្រប់ដំណាក់កាលនៃនីតិវិធីរបស់តុលាការ ។ គោលការណ៍ចំពោះមុខ មានគោលបំណងដើម្បីធ្វើការប្រមូលយកភស្តុតាងឱ្យបានគ្រប់គ្រាន់សមល្មម ដែលអាចធ្វើឱ្យតុលាការចេញសេចក្តីសម្រេចមួយមានភាពត្រឹមត្រូវ និង គ្រប់ជ្រុងជ្រោយ ។ ប៉ុន្តែប្រសិនបើ ភាគីអវត្តមាននៅកាលបរិច្ឆេទដែលតុលាការបានកំណត់នៅក្នុងកិច្ចនីតិវិធីណាមួយ ជាមូលហេតុធ្វើឱ្យការយឺតយ៉ាវ នៃនីតិវិធីរបស់តុលាការខូចប្រយោជន៍របស់ភាគីម្ខាងទៀត និង ធ្វើឱ្យការប្រមូលយកនូវព័ត៌មានមិនបានគ្រប់ជ្រុងជ្រោយសម្រាប់ធ្វើការសេចក្តីសម្រេចប្រកបទៅដោយភាពត្រឹមត្រូវ ។

ម្យ៉ាងវិញទៀត ភាគីដែលអវត្តមានដោយគ្មានមូលហេតុច្បាស់លាស់ ក៏ជាហេតុដែលនាំឱ្យតុលាការធ្វើការសេចក្តីសម្រេចដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ នីតិវិធីទាញហេតុផលដោយផ្ទាល់នោះទេ គឺតុលាការចេញ **សាលក្រមកំបាំងមុខ** តែម្តង ។ ការចេញសេចក្តីសម្រេចដោយមិនបានធ្វើការសាកសួរភាគី វាជាហេតុដែលធ្វើឱ្យប៉ះពាល់ ឬ ខូចប្រយោជន៍របស់ភាគី ។ ដោយហេតុថា សាលក្រមកំបាំងមុខមានការសម្រេចសេចក្តីដោយមិនបានធ្វើការសាកសួរភាគី ទើបក្រមនីតិវិធីរដ្ឋប្បវេណី បានទុកសិទ្ធិឱ្យភាគីដែលតុលាការបានចេញសាលក្រមកំបាំងមុខ មានសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។

ការផ្តល់សិទ្ធិក្នុងធ្វើបណ្តឹងទាស់ ក៏មានកំណត់អំពីចំណុចមួយចំនួន ដើម្បីអាចធ្វើបណ្តឹងទាស់បាន ដែលចំណុចទាំងនោះរួមមាន ល័ក្ខខ័ណ្ឌដែលអាចធ្វើបណ្តឹងទាស់ (១.១) សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ (១.២) និង របៀបធ្វើបណ្តឹងទាស់ និង អានុភាពនៃបណ្តឹងទាស់ (១.៣) ។

## ១.១. ល័ក្ខខ័ណ្ឌដែលអាចធ្វើបណ្តឹងទាស់

មុននឹងធ្វើការបកស្រាយ ទៅលើចំណុចដែលបានរៀបរាប់ខាងលើ យើងខ្ញុំនឹងធ្វើការប្រៀបធៀបរវាងបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ជាមួយបណ្តឹងជំទាស់ចំពោះដីកាសម្រេច ដោយហេតុថាបណ្តឹងទាំងពីរនេះត្រូវបានបុគ្គលមួយចំនួនមានការភាន់ច្រឡំថាជាបណ្តឹងតែមួយ ព្រោះការហៅឈ្មោះរបស់បណ្តឹងទាំងពីរមានលក្ខណៈស្រដៀងគ្នា ។ ប៉ុន្តែជាក់ស្តែង បណ្តឹងទាំងពីរនេះមានអត្ថន័យ និង គោលដៅផ្សេងដាច់ពីគ្នា ដូចមានចែងនៅក្នុងក្រមនីតិវិធីរដ្ឋប្បវេណី ហើយដូចគ្នា

នេះដែរ ដើម្បីឱ្យកាន់តែច្បាស់យើងខ្ញុំនិងបង្ហាញអំពីចំណុចមួយចំនួន ដើម្បីជៀសវាងនូវការភាន់ច្រឡំរវាងបណ្តឹងទាំងពីរនេះ ។

បណ្តឹងទាស់ គឺជាបណ្តឹងមួយដែលធ្វើឡើងនៅពេល ដែលភាគីមិនយល់ស្របទៅនឹងការចេញនូវសាលក្រមកំបាំងមុខ ។ បណ្តឹងទាស់ ជាប្រភេទបណ្តឹងឧបាស្រ័យទៅតុលាការដើម ឬ តុលាការដែលបានសម្រេចសេចក្តី ។ បណ្តឹងទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ គិតចាប់ពីថ្ងៃដែលបានទទួលសាលក្រមកំបាំងមុខ ហើយអំឡុងពេលនេះពុំអាចពន្យាបានឡើយ[1] ។ តុលាការដែលមានសមត្ថកិច្ចទទួលពាក្យបណ្តឹង វិនិច្ឆ័យ និង ការសម្រេចសេចក្តីលើបណ្តឹងទាស់ គឺតុលាការដែលបានចេញនូវសាលក្រមកំបាំងមុខ ។ ចំពោះនីតិវិធីដែលអនុវត្តក្នុងបណ្តឹងទាស់ត្រូវបានកំណត់ដាច់ដោយឡែកពី នីតិវិធីដែលត្រូវអនុវត្តក្នុងបណ្តឹងជំទាស់។

បណ្តឹងជំទាស់ គឺជាបណ្តឹងមួយដែលធ្វើឡើង ដើម្បីទាមទារឱ្យមានការផ្លាស់ប្តូរ ឬ លុបចោលដីកាសម្រេចដើម ។ បណ្តឹងជំទាស់មិនអាចធ្វើបានទៀតឡើយបើមានដីកាសម្រេចលើបណ្តឹងជំទាស់នោះ[2] ។ បណ្តឹងជំទាស់ត្រូវធ្វើក្នុងអំឡុងពេល ១ សប្តាហ៍ គិតចាប់ពីថ្ងៃដែលទទួលដំណឹងអំពីដីកាសម្រេច ហើយរយៈពេលនេះមិនអាចពន្យាបានឡើយ[3] ។ តុលាការដែលមានសមត្ថកិច្ចក្នុងការទទួលបណ្តឹងជំទាស់ ជាតុលាការដែលបានចេញនូវដីកាសម្រេច ។ ចំពោះសមត្ថកិច្ចរបស់តុលាការក្នុងការវិនិច្ឆ័យ និង សម្រេចសេចក្តីលើបណ្តឹងជំទាស់ គឺសាលាឧទ្ធរណ៍ ។ ចំណែកឯ នីតិវិធី ដែលត្រូវយកមកអនុវត្ត ចំពោះបណ្តឹងជំទាស់ត្រូវបានកំណត់ដោយឡែកពី នីតិវិធីដែលត្រូវអនុវត្តក្នុងបណ្តឹងទាស់។

សរុបមក បន្ទាប់ពីបានធ្វើការបកស្រាយខាងលើរួចមក បានបង្ហាញឱ្យឃើញថា បណ្តឹងទាំងពីរនេះ មានគោលបំណង និង គោលដៅផ្ទុយពីគ្នា ដោយបណ្តឹងទាស់ គឺធ្វើឡើងដើម្បីប្រឆាំងទៅនឹងសាលក្រមកំបាំងមុខ ។ រីឯបណ្តឹងជំទាស់ គឺធ្វើឡើងក្នុងគោលបំណងប្រឆាំងទៅនឹងដីកាសម្រេច ។ ហើយចំពោះសមត្ថកិច្ចរបស់តុលាការ ក្នុងការវិនិច្ឆ័យ និង សម្រេចសេចក្តី ក៏ជាសមត្ថកិច្ចរបស់តុលាការ ២ (ពីរ) ផ្សេងគ្នា ។ ម្យ៉ាងវិញទៀត នីតិវិធីដែលត្រូវយកមកប្រើសម្រាប់ចំណាត់ការចំពោះបណ្តឹងទាំង ២(ពីរ) ខាងលើនេះ ក៏មានភាពដាច់ដោយឡែកពីគ្នា ។ ដូច្នេះអាចសន្និដ្ឋានបានថា បណ្តឹងទាស់ និង បណ្តឹងជំទាស់ ជាប្រភេទបណ្តឹង ២ (ពីរ) ផ្សេងដាច់ពីគ្នា ។

[1] មាត្រា ២០៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

[2] មាត្រា ២៥៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

[3] មាត្រា ៣០៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

បន្ទាប់ពីបានបកស្រាយ និង ធ្វើការវែកញែកពីភាពខុសគ្នានៃបណ្ដឹងទាំងពីរួចមក យើងក្រឡេកមកមើលល័ក្ខខ័ណ្ឌដែលអាចធ្វើបណ្ដឹងទាស់វិញម្ដង ដែលបណ្ដឹងទាស់អាចធ្វើឡើងបានដោយត្រូវពិចារណាល័ក្ខខ័ណ្ឌពីរសំខាន់ៗ៖ ទី១ សាលក្រមដែលអាចធ្វើបណ្ដឹងទាស់ (១.១.១) និង ទី២ អំឡុងពេលដែលអាចធ្វើបណ្ដឹងទាស់បាន (១.១.២) ។

### ១.១.១ សាលក្រមដែលអាចធ្វើបណ្ដឹងទាស់

ប្រសិនបើ ភាគីមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលាដែលបានកំណត់ ដោយមូលហេតុដែលមិនអាចធ្វើការព្យាករ ឬ ដោយសារមូលហេតុដែលមិនអាចជៀសវាងបាន ដែលជាហេតុនាំឱ្យតុលាការចេញនូវសាលក្រមកំបាំងមុខជាដើម ។

បណ្ដឹងទាស់ គឺជាបណ្ដឹងឧបាស្រ័យរបស់ភាគីដែលពុំយល់ស្រប ជាមួយសាលក្រមកំបាំងមុខរបស់ចៅក្រម ឬ តុលាការ ដើម្បីទាមទារឱ្យមានការលុបចោល ឬ ផ្លាស់ប្ដូរសាលក្រមកំបាំងមុខ។

សាលក្រមដែលអាចធ្វើបណ្ដឹងទាស់បានរួមមាន៖ សាលក្រមកំបាំងមុខដើមចោទ (១.១.១.១) និង សាលក្រមកំបាំងមុខចុងចម្លើយ (១.១.១.២) ដែលនឹងធ្វើការបកស្រាយលម្អិត និង មានភាពស៊ីជម្រៅនៅចំណុចខាងក្រោមទៅលើល័ក្ខខ័ណ្ឌក៏ដូចជាមូលហេតុ ដែលនាំឱ្យតុលាការសម្រេចសេចក្ដីដោយចេញនូវសាលក្រមកំបាំងមុខឡើង ។

#### ១.១.១.១. សាលក្រមកំបាំងមុខដើមចោទ

សាលក្រមកំបាំងមុខដើមចោទ ជាសាលក្រមដែលធ្វើឡើងចំពោះដើមចោទ ដោយសារតែដើមចោទមិនបានចូលបង្ហាញខ្លួននៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ។ ករណីនេះ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទ ដោយការចេញនូវសាលក្រមកំបាំងមុខដើមចោទ[៦] ។ ការមិនបង្ហាញខ្លួនរបស់ដើមចោទនាកាលបរិច្ឆេទលើកទី១ ជាហេតុធ្វើឱ្យតុលាការយល់ឃើញថាដើមចោទមិនមានឆន្ទៈក្នុងការបន្តនីតិវិធីបន្តទៀតនោះទេ ។ ការយល់ឃើញបែបនេះនាំឱ្យតុលាការធ្វើការសម្រេចសេចក្ដីច្រានចោលការទាមទាររបស់ដើមចោទ ដោយចេញសាលក្រមកំបាំងមុខ ដោយមិនចាំបាច់ឆ្លងកាត់នីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះទេ ។

ប្រសិនបើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលនោះទេ តុលាការនឹងបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលភ្លាមៗ ដោយធ្វើការកំណត់កាលបរិច្ឆេទលើកទី១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ។ បន្ទាប់ពីកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលបានកំណត់មកដល់ ភាគីដើមចោទនៅតែបន្តអវត្តមាន

[៦] មាត្រា២០០ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

តុលាការ នឹងធ្វើការច្រានចោលការទាមទាររបស់ដើមចោទ ដោយការចេញនូវសាលក្រមកំបាំងមុខដើមចោទ[៥] ។

### ១.១.១.២. សាលក្រមកំបាំងមុខចុងចម្លើយ

សាលក្រមកំបាំងមុខចុងចម្លើយ គឺជាសាលក្រមដែលធ្វើឡើងចំពោះចុងចម្លើយ បើចុងចម្លើយមិនបានចូលបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ហើយតុលាការត្រូវបញ្ចប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផលដោយភ្លាមៗ និង កំណត់នូវកាលបរិច្ឆេទលើកទី១នៃការទាញហេតុផលដោយផ្ទាល់មាត់ ។

ម្យ៉ាងវិញទៀត ប្រសិនបើកាលបរិច្ឆេទនៃនីតិវិធីការទាញហេតុផលដោយផ្ទាល់មាត់ បានមកដល់ ភាគីចុងចម្លើយមិនបានចូលបង្ហាញខ្លួន ក្នុងការទាញហេតុផលដោយផ្ទាល់មាត់នោះទេ តុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទ ដែលទាក់ទងនឹងអង្គហេតុ ។ ករណីនេះ តុលាការអាចទទួលស្គាល់ការទាមទាររបស់ដើមចោទដោយសាលក្រមកំបាំងមុខចុងចម្លើយ ប្រសិនបើយល់ឃើញថាការទាមទាររបស់ដើមចោទមានភាពត្រឹមត្រូវ ។ ផ្ទុយទៅវិញ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទ ប្រសិនបើតុលាការយល់ឃើញថាការទាមទាររបស់ដើមចោទមិនត្រឹមត្រូវ ។ ប៉ុន្តែករណីនេះមិនត្រូវបានអនុវត្តឡើយ ប្រសិនបើចុងចម្លើយធ្វើវិវាទលើការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ពីមុនមក[៦] ។

ក្រោយពីតុលាការសម្រេចសេចក្តីដោយបានចេញនូវសាលក្រមកំបាំងមុខ តុលាការបានទុកសិទ្ធិឱ្យភាគីធ្វើនូវបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ និង កំណត់អំពីអំឡុងពេលសម្រាប់ធ្វើនូវបណ្តឹងទាស់ ដែលអំឡុងពេលនៃការធ្វើបណ្តឹងទាស់ ត្រូវយកមកសិក្សាស្រាវជ្រាវនៅចំណុចបន្ទាប់ ។

### ១.១.២. អំឡុងពេលដែលអាចធ្វើបណ្តឹងទាស់បាន

បណ្តឹងទាស់ គឺជាបណ្តឹងឧបាស្រ័យមួយប្រភេទ ដែលមានកម្មវត្ថុទាមទារឱ្យតុលាការដែលបានជម្រះក្តី ធ្វើការវិនិច្ឆ័យសារជាថ្មីម្តងទៀតទៅលើសាលក្រមកំបាំងមុខ ។

[៥] មាត្រា ២០០ កថាខណ្ឌទី២ និងទី៣ ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦] មាត្រា ២០១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

បណ្តឹងទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខ[៧] ។ ប៉ុន្តែប្រសិនបើសាលក្រមកំបាំងមុខ ត្រូវបានបញ្ជូនតាមរយៈការផ្សាយជាសាធារណៈ ឬ តាមរយៈការបញ្ជូនដែលត្រូវធ្វើនៅបរទេស តុលាការត្រូវកំណត់អំឡុងពេលដែលអាចធ្វើបណ្តឹងទាស់ នៅក្នុងសាលក្រមកំបាំងមុខនោះតែម្តង[៨] ។ បន្ថែមលើពីនេះទៅទៀតអំឡុងពេលសម្រាប់ធ្វើបណ្តឹងទាស់ពុំអាចពន្យាបានឡើយ ។ ទន្ទឹមការកំណត់អំពីអំឡុងពេលសម្រាប់ធ្វើនូវបណ្តឹងទាស់ ក៏តម្រូវឱ្យភាគីដែលធ្វើបណ្តឹងទាស់មានសិទ្ធិក្នុងការធ្វើនូវបណ្តឹងទាស់ ដែលសិទ្ធិទាំងនោះ នឹងត្រូវលើកយកមកធ្វើការបកស្រាយ ឱ្យមានភាពច្បាស់លាស់នៅក្នុងចំណុចបន្ទាប់ ។

## ១.២. សិទ្ធិក្នុងការធ្វើបណ្តឹងទាស់

សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ គឺជាល័ក្ខខ័ណ្ឌមួយដ៏សំខាន់ដែលតម្រូវឱ្យភាគីដាច់ខាតតែត្រូវមាននៅពេលដែលធ្វើបណ្តឹង ។ បើភាគីដែលមានបំណងក្នុងការធ្វើបណ្តឹងមិនមានសមត្ថភាពក្នុងការបំពេញឱ្យបានគ្រប់គ្រាន់ទៅតាមល័ក្ខខ័ណ្ឌដែលច្បាប់តម្រូវឱ្យមាននោះទេ គាត់ក៏មិនមានសិទ្ធិក្នុងការធ្វើនូវបណ្តឹងបានផងដែរ ។ ចំពោះល័ក្ខខ័ណ្ឌដើម្បីទទួលបាននូវសិទ្ធិ ក្នុងការធ្វើបណ្តឹងទាស់ឱ្យមានភាពត្រឹមត្រូវតាមច្បាប់ដែលបានកំណត់ ត្រូវស្វែងយល់នូវចំណុច សមត្ថភាពរបស់ភាគីក្នុងការធ្វើនូវបណ្តឹងជាមុនសិន ។

### ១.២.១. សមត្ថភាពភាគីក្នុងការធ្វើបណ្តឹងទាស់

មុននឹងឈានដល់ការបកស្រាយលម្អិតទៅលើ សមត្ថភាពភាគី ក្នុងការធ្វើបណ្តឹងយើងត្រូវស្វែងយល់លើនិយមន័យ និង គោលបំណងនៃពាក្យថា សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្តឹង និង ពាក្យថា បណ្តឹង ជាមុនសិន ។ ពាក្យថា សមត្ថភាពភាគី សំដៅទៅលើបុគ្គលដែលមានសិទ្ធក្នុងការទាមទារឱ្យមាននូវសេចក្តីសម្រេចរបស់តុលាការក្នុងនាមខ្លួន ដើម្បីដោះស្រាយវិវាទ និង ជាបុគ្គលដែលមានសិទ្ធិទាមទារឱ្យចង្អុលឈ្មោះបុគ្គល ដែលត្រូវបានទាមទារនោះនៅក្នុងសេចក្តីសម្រេចរបស់តុលាការផងដែរ ។ ពាក្យថា សមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាលក្ខណៈសម្បត្តិដែលភាគី ឬ បុគ្គលដែលពាក់ព័ន្ធក្នុងនីតិវិធីបណ្តឹង អាចធ្វើសកម្មភាពបណ្តឹងដោយខ្លួនឯងបានឱ្យមានអានុភាព ឬ ទទួលនូវសកម្មភាពបណ្តឹងរបស់តុលាការ និង ភាគីម្ខាងទៀតបានតាមផ្លូវច្បាប់ ។ ចំពោះពាក្យថា បណ្តឹង គឺជាសកម្មភាពទាមទាររបស់ដើមចោទចំពោះចុងចម្លើយ ដើម្បីឱ្យតុលាការចេញសាលក្រម ដោយផ្អែកលើការអះអាងអំពីអត្ថិភាព ឬ នត្ថិភាពនៃសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តណាមួយតាមច្បាប់កំណត់ ។

[៧] មាត្រា ២០៤ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦
[៨] មាត្រា ២០៤ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

ក្រោយពីបានធ្វើការបកស្រាយនូវពាក្យថា សមត្ថភាពភាគី សមត្ថភាពក្នុងការធ្វើបណ្ដឹង និង ពាក្យថា បណ្ដឹង អាចនិយាយបានថា សមត្ថភាពភាគីក្នុងការធ្វើបណ្ដឹង សំដៅទៅលើសិទ្ធិក្នុងការទាមទារឱ្យមាននូវសេចក្ដីសម្រេចរបស់តុលាការ ។ ភាគីដែលធ្វើការទាមទារឱ្យមានសេចក្ដីសម្រេចរបស់តុលាការ គឺជាបុគ្គលដែលមានលក្ខណៈសម្បត្តិ ឬ ជាបុគ្គលដែលពាក់ព័ន្ធក្នុងនីតិវិធីបណ្ដឹង ហើយភាគីនោះអាចធ្វើសកម្មភាពបណ្ដឹងឱ្យមានអានុភាពដោយខ្លួនឯង អាចទទួលនូវសកម្មភាពបណ្ដឹងរបស់តុលាការ និង សកម្មភាពរបស់ភាគីម្ខាងទៀតបានតាមផ្លូវច្បាប់បាន ។ ទោះបីជាបុគ្គលនោះមានសមត្ថភាពក៏ដោយ តែប្រសិនបើសាមីខ្លួនពុំមានសមត្ថភាពអាចយល់បាននូវគោលគំនិត ឬ អានុភាពនៃសកម្មភាពនៅពេលដែលបានធ្វើ ឬ ទទួលសកម្មភាពនៃនីតិវិធីបណ្ដឹងបានទេ អាចនិយាយបានយ៉ាងប្រាកដថាបុគ្គលនោះ មិនអាចការពារផលប្រយោជន៍របស់ខ្លួនតាមបណ្ដឹងបានឡើយ ។ ក្រមនីតិវិធីរដ្ឋប្បវេណីបានផ្ដល់ និង ធានាឱ្យបុគ្គលគ្រប់រូបមានសិទ្ធិទទួលបានការពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី[៦] ។ ស្របពេលដែលក្រមនីតិវិធីរដ្ឋប្បវេណី បានធានាសិទ្ធិក្នុងការពឹងពាក់តុលាការចំពោះបុគ្គលគ្រប់រូប ក៏មិនមែនបានន័យថា បុគ្គលគ្រប់រូបនោះ អាចមានសមត្ថភាពធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងបានឡើយ ។ ដោយឃើញថាបុគ្គលមួយចំនួនមិនអាចធ្វើសកម្មភាពបណ្ដឹងដោយខ្លួនឯងបាន ឬ មិនអាចការពារនូវផលប្រយោជន៍របស់ខ្លួនបាន ទើបច្បាប់បានបើកសិទ្ធិឱ្យបុគ្គលដែលមិនអាចធ្វើសកម្មភាពបណ្ដឹងបានដោយខ្លួនឯងផ្ទាល់ ឬ បុគ្គល ដែលមិនអាចការពារនូវផលប្រយោជន៍របស់ខ្លួននោះ អាចជ្រើសរើសអ្នកតំណាង ក្នុងការធ្វើសកម្មភាពដើម្បីការពារនូវផលប្រយោជន៍របស់ខ្លួនបាន ។

ជាទូទៅ ភាគីដែលពុំមានសមត្ថភាពគ្រប់គ្រាន់ មិនអាចឆ្លើយតបភ្លាមៗចំពោះការអះអាងរបស់ភាគីម្ខាងទៀត ឬ ដាក់ភស្តុតាងដើម្បីបញ្ជាក់ការអះអាងរបស់ខ្លួនបានទេ ។ កត្តានេះ នឹងនាំឱ្យភាគីដែលពុំមានសមត្ថភាពចាញ់ ទាំងខ្លួនមានលទ្ធភាពក្នុងការឈ្នះក្ដី ។ ដូច្នេះ ដើម្បីការពារបុគ្គលដែលពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអះអាង និង ការពារផលប្រយោជន៍របស់ខ្លួនតាមបណ្ដឹង ច្បាប់បានបង្កើតនូវរបបនៃសមត្ថភាពក្នុងការធ្វើបណ្ដឹង ដោយចាត់ទុកថា បុគ្គលទាំងនោះពុំមានលក្ខណៈសម្បត្តិធ្វើសកម្មភាពក្នុងការធ្វើបណ្ដឹងបានទេ ដោយឱ្យអ្នកតំណាងដែលច្បាប់បានកំណត់ធ្វើសកម្មភាពបណ្ដឹងជំនួសបុគ្គលទាំងនោះ ។

ជាគោលការណ៍ ការកំណត់លើបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើបណ្ដឹង ត្រូវបានកំណត់តាមបញ្ញត្តិនៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា មកធ្វើជាមូលដ្ឋាន ។ ក្នុងក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិអំពីល័ក្ខខ័ណ្ឌ និង សមត្ថភាពក្នុងការធ្វើបណ្ដឹងរបស់ អនីតិជន

[៦] មាត្រា ២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

ជននៅក្រោមអាណាព្យាបាលទូទៅ ១.២.១.១ ជននៅក្រោមហិតូបត្ថម្ភ ១.២.១.២ ជនបរទេស ១.២.១.៣ និង អ្នកតំណាងដោយអាណត្តិ ១.២.១.៤ ។

### ១.២.១.១. អនីតិជន និង ជននៅក្រោមអាណាព្យាបាលទូទៅ

អនីតិជន សំដៅទៅលើជនដែលមានអាយុក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ[១០] ។ ចំណែកឯជននៅក្រោមអាណាព្យាបាលទូទៅ សំដៅជនដែលតុលាការបានប្រកាស ចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅដ្ឋានរបស់ជននោះ ឬ តំណាងអយ្យការ ដោយមូលហេតុស្ថានភាពជានិរន្តន៍ដែលខ្វះសមត្ថភាពក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។ ប៉ុន្តែលើកលែង ចំពោះករណីដែលសាមីខ្លួនមិនទាន់ដល់អាយុ ១៥ (ដប់ប្រាំ) ឆ្នាំ នៅពេលដែលមានពាក្យសុំ[១១] ត្រូវហៅថា ជននៅស្ថិតក្រោមអាណាព្យាបាលទូទៅ ហើយត្រូវស្ថិតនៅក្រោមអ្នកអាណាព្យាបាលទូទៅ[១២] ។

ជាគោលការណ៍ ជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព ដែលមានអនីតិជន ជនដែលនៅក្រោមអាណាព្យាបាលទូទៅ[១៣] ពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹងទេ លើកលែងតែសកម្មភាពបណ្តឹងត្រូវបានធ្វើតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់[១៤] ។ សកម្មភាពបណ្តឹងអាចត្រូវបានលុបចោល ប្រសិនបើអនីតិជន ឬ ជនដែលនៅក្រោមអាណាព្យាបាលទូទៅបានធ្វើសកម្មភាពបណ្តឹងដោយមិនបានទទួលការយល់ព្រមពីអ្នកតំណាងដែលច្បាប់បានកំណត់ ។

ប៉ុន្តែ ចំពោះអនីតិជនដែលទទួលបានអគ្គាធីនភាពត្រូវបានចាត់ទុកថា បានដល់នីតិភាព[១៥] ហើយអនីតិជននោះនឹងមានសមត្ថភាពក្នុងការធ្វើបណ្តឹងបានយ៉ាងពេញលេញ ។ ក្រៅអំពី អនីតិជន និង ជនដែលនៅក្រោមអាណាព្យាបាលទូទៅ ក៏មាន ជននៅក្រោមហិតូបត្ថម្ភ ដែលនឹងត្រូវលើកយកមកបកស្រាយនៅចំណុចបន្ទាប់ ។

### ១.២.១.២. ជននៅក្រោមហិតូបត្ថម្ភ

ជននៅក្រោមហិតូបត្ថម្ភ សំដៅដល់ជនដែលត្រូវបានតុលាការប្រកាសចាប់ផ្តើមហិតូបត្ថម្ភតាម

[១០] មាត្រា ១៧ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[១១] មាត្រា ២៤ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[១២] មាត្រា ២៥ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[១៣] មាត្រា ១៦ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[១៤] មាត្រា ៣២ កថាខណ្ឌទី ៣ វាក្យខណ្ឌទី ១ នៃនីតិវិធីក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[១៥] មាត្រា ២២ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

ពាក្យសុំរបស់សាមីខ្លួន សហព័ន្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ[១៦] ដោយមូលហេតុមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួនដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ។

សកម្មភាពបណ្តឹង ជននៅក្រោមហិតូបត្ថម្ភត្រូវទទួលការយល់ព្រមពីហិតូបត្ថម្ភកៈ[១៧] ។ ការយល់ព្រមនេះ ត្រូវធ្វើការបញ្ជាក់ដោយលិខិតជាលាយល័ក្ខណ៍អក្សរ[១៨] ។

ដោយឡែកការធ្វើសកម្មភាពតបចំពោះបណ្តឹង ឬ បណ្តឹងឧបាស្រ័យទៅតុលាការជាន់ខ្ពស់ដែលត្រូវបានធ្វើឡើងដោយភាគីម្ខាងទៀត ជនស្ថិតនៅក្រោមហិតូបត្ថម្ភអាចធ្វើបាន ដោយមិនចាំបាច់មានការយល់ព្រមពីហិតូបត្ថម្ភកៈឡើយ[១៩] ។

### ១.២.១.៣. ជនបរទេស

ដោយគោរពតាមគោលការណ៍អធិបតេយ្យនៃរដ្ឋមួយ មាត្រា៣២ នៃក្រមនីតិវិធីរដ្ឋប្បវេណីបានកំណត់ឱ្យជនបរទេសដែលចង់ធ្វើសកម្មភាពបណ្តឹងត្រូវតែគោរព និង ប្រតិបត្តិតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះជនបរទេសត្រូវចាត់ទុកជាបុគ្គលដែលមានសមត្ថភាពក្នុងការធ្វើសកម្មភាពបណ្តឹង ប្រសិនបើជនបរទេសនោះ មានសមត្ថភាពក្នុងការធ្វើបណ្តឹងដោយយោងតាមបញ្ញត្តិច្បាប់កម្ពុជា ទោះពុំមានសមត្ថភាពតាមច្បាប់របស់ខ្លួនក៏ដោយ[២០] ។

### ១.២.១.៤. អ្នកតំណាងដោយអាណត្តិ

ជាគោលការណ៍ អ្នកតំណាងដោយអាណត្តិត្រូវតែជាមេធាវី ។ ក្នុងករណីដែលជនក្រៅពីមេធាវី បានធ្វើសកម្មភាពបណ្តឹង ក្នុងនាមជាអ្នកតំណាងដោយអាណត្តិ នោះជាអំពើខុសនឹងច្បាប់ ហើយរាល់សកម្មភាពបណ្តឹងដែលជននោះបានធ្វើក្នុងនាមភាគី ពុំមានសុពលភាពឡើយ លើកលែងតែភាគីបានផ្តល់សច្ចានុមតិលើសកម្មភាពបណ្តឹងនោះ ទើបអាចមានសុពលភាពបាន[២១] ។ ប៉ុន្តែមានករណីលើកលែងមួយចំនួន ដែលច្បាប់ទទួលស្គាល់ការជ្រើសតាំងជនក្រៅពីមេធាវីឱ្យធ្វើជាអ្នកតំណាង ដោយអាណត្តិ ដូចជា ៖

---

[១៦] មាត្រា ២៨ កថាខណ្ឌទី ១ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧

[១៧] មាត្រា ៣០ ចំណុច ឃ នៃក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[១៨] មាត្រា ៣៥ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[១៩] មាត្រា ៣៣ កថាខណ្ឌទី ១ នៃនីតិវិធីក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២០] មាត្រា ៣៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២១] មាត្រា ៥៧ កថាខណ្ឌ ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

-ច្បាប់អនុញ្ញាតឱ្យតតិយជនដែលមិនមែនជាមេធាវី ធ្វើសកម្មភាពបណ្តឹងជំនួសភាគី

-បុគ្គលិកនៃស្ថាប័នរដ្ឋ ត្រូវតែងតាំងជាអ្នកតំណាងដោយអាណត្តិឱ្យស្ថាប័នដែលជាភាគី

-តុលាការអនុញ្ញាតឱ្យមានការតំណាងដោយតតិយជន ដែលមិនមែនជាមេធាវី ក្នុងរឿងក្តីចំនួនទឹកប្រាក់តិច ដែលតម្លៃកម្មវត្ថុនៃបណ្តឹងមិនលើសពី ១.០០០.០០០ (មួយលានរៀល)[២២] ។

ការតំណាងដោយអាណត្តិ ត្រូវធ្វើឡើងដោយការបង្ហាញឆន្ទៈរបស់ភាគី ប៉ុន្តែទោះបីជាភាគីបានប្រគល់សិទ្ធិតំណាងឱ្យទៅអ្នកតំណាងដោយអាណត្តិក៏ដោយ ក៏ភាគីនៅតែអាចចូលតុលាការដើម្បីទាញហេតុផលដោយផ្ទាល់មាត់ដោយខ្លួនឯងបាន[២៣] ។ សិទ្ធិអំណាចរបស់អ្នកតំណាងដោយអាណត្តិត្រូវធ្វើជាលាយលក្ខណ៍អក្សរ[២៤] ។ ចំពោះសកម្មភាពបណ្តឹងដែលធ្វើឡើងដោយអ្នកតំណាងដោយអាណត្តិមានអានុភាពដូចសកម្មភាពដែលធ្វើដោយភាគីដែរ ប៉ុន្តែអ្នកតំណាងដោយអាណត្តិ មិនទទួលនូវអានុភាពនៃសាលក្រមដូចភាគីនោះទេ ។ ម្យ៉ាងទៀត ប្រសិនបើអ្នកតំណាងដោយអាណត្តិបានសារភាព ឬ ផ្តល់ចម្លើយទាក់ទងនឹងអង្គហេតុ ចម្លើយរបស់អ្នកតំណាងដោយអាណត្តិមិនមានអានុភាពឡើយ ប្រសិនបើភាគីដែលជាម្ចាស់សិទ្ធិបានលុបចោល ឬ កែតម្រូវភ្លាមៗចំពោះសកម្មភាពនោះ[២៥] ។

### ១.២.២. អានុភាពតាមផ្លូវច្បាប់នៃសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់

សមត្ថភាពក្នុងការធ្វើបណ្តឹង គឺជាល័ក្ខខ័ណ្ឌសុពលភាពនៃសកម្មភាពបណ្តឹងនីមួយៗ ហើយសកម្មភាពរបស់ជន ដែលគ្មានសមត្ថភាពក្នុងការធ្វើបណ្តឹងនឹងត្រូវចាត់ទុកជាមោឃៈ ដែលហេតុនាំឱ្យមិនមានស្ថិរភាពក្នុងនីតិវិធីនៃបណ្តឹង ។ ដូចនេះដើម្បីឱ្យមានស្ថិរភាពក្នុងនីតិវិធីបណ្តឹង តុលាការអាចធ្វើការស្រាវជ្រាវអំពីអត្ថិភាព ឬ នត្ថិភាពនៃសមត្ថភាពក្នុងការធ្វើបណ្តឹង ដោយឆន្ទានុសិទ្ធិរបស់ខ្លួនបាន ។

ដើម្បីឱ្យនីតិវិធីនៃរឿងក្តីមានអានុភាពតាមផ្លូវច្បាប់ ភាគីនៃរឿងក្តីត្រូវជៀសវាងនូវចំណុចមួយចំនួនដែលត្រូវបានហាមឃាត់ ក្នុងនោះរួមមាន ៖ ករណីខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង (១.២.២.១) និង ឥទ្ធិពលទៅលើបណ្តឹងនៃការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង (១.២.២.២) ។

[២២] មាត្រា ៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២៣] មាត្រា ៥២ កថាខណ្ឌ ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

[២៤] មាត្រា ៥៣ កថាខណ្ឌ ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

[២៥] មាត្រា ៥២ កថាខណ្ឌ ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

### ១.២.២.១. ករណីខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់

រាល់សកម្មភាពបណ្តឹងដែលបានធ្វើឡើង ដោយបុគ្គលដែលខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ ខ្វះសិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ខ្វះការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង ត្រូវមានអានុភាពប្រតិសកម្មតាំងពីពេលដែលសកម្មភាពនោះបានធ្វើឡើង បើមានការទទួលស្គាល់ ឬ កាផ្តល់នូវសច្ចានុមតិនៅពេលក្រោយ ដោយភាគីដែលបានទទួលសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ ដោយអ្នកតំណាង[២៦] ។

មួយវិញទៀតករណីដែលមានការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ សិទ្ធិតំណាងដែលច្បាប់បានកំណត់ ឬ ការប្រគល់សិទ្ធិចាំបាច់សម្រាប់ធ្វើសកម្មភាពបណ្តឹង តុលាការត្រូវបង្គាប់ឱ្យកែតម្រូវនូវចំណុចដែលខ្វះខាត ដោយកំណត់អំឡុងពេលសម្រាប់កែតម្រូវ ។ ប្រសិនបើមានការខូចខាតណាមួយអាចកើតឡើង ដោយសារការយឺតយ៉ាវតុលាការអាចឱ្យបុគ្គល ដែលមានការខ្វះនោះ ធ្វើសកម្មភាពបណ្តឹងជាបណ្តោះអាសន្នបាន[២៧] ។

### ១.២.២.២. ឥទ្ធិពលនៅលើបណ្តឹងនៃការខ្វះសមត្ថភាពក្នុងការធ្វើបណ្តឹងទាស់

ក្នុងករណីដើមចោទពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹង នៅពេលដាក់ពាក្យបណ្តឹង ឬ ចុងចម្លើយពុំមានសមត្ថភាពក្នុងការធ្វើបណ្តឹង នៅពេលដែលបានទទួលនូវការបញ្ជូនពាក្យបណ្តឹង តុលាការត្រូវលើកចោលពាក្យបណ្តឹងដោយសារមូលហេតុមិនស្របច្បាប់ ប្រសិនបើពុំមានការកែតម្រូវនូវចំណុចដែលខ្វះ[២៨]នោះដូចជា ការទទួលយល់ព្រមពីអ្នកមានអំណាចមេបា ក្នុងករណីភាគីជាអនីតិជន ការទទួលយល់ព្រមពីអ្នកអាណាព្យាបាលទូទៅ ក្នុងករណីភាគីជាជននៅក្រោមអាណាព្យាបាលទូទៅ និង ការទទួលយល់ព្រមពីហិតូបត្ថម្ភកៈ ក្នុងករណីភាគីជាជននៅក្រោមហិតូបត្ថម្ភ។

ម្យ៉ាងទៀត ក្នុងករណីដែលខ្វះនូវសមត្ថភាពក្នុងការធ្វើបណ្តឹងរបស់ភាគី កើតមានឡើងក្រោយពេលដែលបានចាត់ការលើបណ្តឹង ដូចជាបាត់បង់នូវសមត្ថភាពក្នុងការធ្វើបណ្តឹង ឬ មរណភាពរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ឬ ការរំលត់នូវសិទ្ធិតំណាង នោះនីតិវិធីបណ្តឹងត្រូវផ្អាក ហើយបុគ្គលដែលត្រូវបន្តនីតិវិធីនៃបណ្តឹង គឺអ្នកតំណាងដែលច្បាប់បានកំណត់ ដែលត្រូវជ្រើសតាំងថ្មី ឬ ភាគីមានសមត្ថភាពក្នុងការធ្វើបណ្តឹងឡើងវិញ[២៩]។

---

[២៦] មាត្រា ៣៥ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២៧] មាត្រា ៣៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[២៨] មាត្រា៧៨ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦

[២៩] មាត្រា ១៧៣ កថាខណ្ឌទី ១ ចំណុច គ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ទន្ទឹមនឹងការកំណត់ឱ្យបំពេញនូវល័ក្ខខ័ណ្ឌ ដើម្បីទទួលបាននូវសិទ្ធិ ក្នុងការបណ្តឹងធ្វើបណ្តឹងទាស់ ច្បាប់ក៏បានទុកសិទ្ធិឱ្យភាគីក្នុងការសម្រេចចិត្តដើម្បីធ្វើបណ្តឹងទាស់ ឬ ក៏លះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ដោយធ្វើបណ្តឹងឧទ្ធរណ៍តែម្តង ។ ល័ក្ខខ័ណ្ឌដែលត្រូវបំពេញដើម្បីទទួលបានសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ការលះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់នឹងត្រូវបានលើកយកមកធ្វើការបកស្រាយនៅចំណុចខាងក្រោមជាបន្តបន្ទាប់ ។

### ១.២.៣. ការលះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់

ការលះបង់សិទ្ធិក្នុងការធ្វើបណ្តឹងទាស់ គឺជាសិទ្ធិមួយដែលច្បាប់បានផ្តល់ឱ្យភាគី ក្នុងការសម្រេចថា ខ្លួនគួរធ្វើបណ្តឹងទាស់ ឬ ក៏មិនគួរធ្វើបណ្តឹងទាស់ ដោយធ្វើបណ្តឹងឧទ្ធរណ៍តែម្តង តាមការជ្រើសរើសរបស់ភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ ។ ច្បាប់មិនបានចាប់បង្ខំឱ្យភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ ត្រូវតែធ្វើបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខនោះទេ ។

## ១.៣. របៀបធ្វើបណ្តឹងទាស់ និង អានុភាពនៃបណ្តឹងទាស់

បន្ទាប់ពីបានបំពេញនូវល័ក្ខខ័ណ្ឌ ក្នុងការធ្វើបណ្តឹងទាស់ ភាគីដែលមានបំណងធ្វើបណ្តឹងទាស់អាចដាក់ពាក្យបណ្តឹងតាមរបៀបនៃការធ្វើបណ្តឹងទាស់ (១.៣.១) ដែលនឹងរៀបរាប់ខាងក្រោម ។ នៅពេលដែលពាក្យបណ្តឹងត្រូវបានដាក់តាមរបៀបនៃការធ្វើបណ្តឹងទាស់រួចហើយ បណ្តឹងទាស់នោះនឹងបង្កើតនូវអានុភាពមួយចំនួន ដែលនឹងធ្វើបង្ហាញនៅក្នុងចំណុចស្តីពី អានុភាពនៃការធ្វើបណ្តឹងទាស់ (១.៣.២) ។

### ១.៣.១. របៀបធ្វើបណ្តឹងទាស់

ការប្តឹងទាស់ ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្តឹងទៅតុលាការ ដែលបានចេញសាលក្រមកំបាំងមុខ[៣០] ស្របទៅតាមទម្រង់ដែលច្បាប់បានកំណត់ ។ ដូច្នេះហើយដើម្បីឱ្យការធ្វើបណ្តឹងទាស់មានអានុភាព នឹងត្រូវបានតុលាការទទួលស្គាល់ ការធ្វើបណ្តឹងទាស់ត្រូវធ្វើតាមទម្រង់ដែលបានកំណត់ក្នុងបញ្ញត្តិមាត្រា ២០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៦ ដោយសរសេរនូវចំណុចដូចខាងក្រោម ៖

-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

[៣០] មាត្រា ២០៥ កថាខណ្ឌទី ១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០១៦

-សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់ ។

-បំណាងនៃការប្តឹងទាស់ចំពោះសាលក្រមដែលជាកម្មវត្ថុនៃការប្តឹងទាស់ ។

-មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ។

**១.៣.២. អានុភាពនៃបណ្តឹងទាស់**

ប្រសិនបើភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ បានធ្វើនូវបណ្តឹងទាស់ បណ្តឹងទាស់នឹងចាប់ផ្តើមមានអានុភាព នៅពេលដែលបណ្តឹងទាស់ត្រូវបានធ្វើឡើង ដោយភាគីដែលត្រូវបានតុលាការសម្រេចចេញនូវសាលក្រមកំបាំងមុខ ឬ ដើមចោទនៃបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ដែលបានដាក់ពាក្យបណ្តឹងទាស់ចូលទៅកាន់តុលាការ ។ ពាក្យបណ្តឹងទាស់នោះ ត្រូវបានទទួលដោយលេខាធិការដ្ឋាន នៃសាលាដំបូង ដែលបានចេញនូវសាលក្រមកំបាំងមុខដែលជាអ្នកទទួលបន្ទុកក្នុងការទទួលពាក្យបណ្តឹងទាស់ ។ បន្ទាប់ពីបានដាក់ពាក្យបណ្តឹងទាស់ទៅលេខាធិការដ្ឋាននៃសាលាដំបូងដែលមានសមត្ថកិច្ចក្នុងការទទួល និង វិនិច្ឆ័យលើបណ្តឹងទាស់រួចមក បណ្តឹងទាស់នឹងកើតមានអានុភាព ដែលអានុភាពនៃបណ្តឹងទាស់មាន ២ (ពីរ) យ៉ាងគឺៈ

ទី១. បណ្តឹងទាស់ មានអានុភាពផ្អាកនូវការចូលជាស្ថាពរនៃសាលក្រមកំបាំងមុខ ។ មានន័យថា ទោះបីជាអំឡុងពេលសម្រាប់ធ្វើបណ្តឹងទាស់ត្រូវបានផុតក៏ដោយ ក៏សាលក្រមកំបាំងមុខនោះមិនអាចចូលស្ថាពរបានដែរ ហើយសេចក្តីសម្រេចនៃសាលក្រមកំបាំងមុខនោះ ក៏មិនអាចអនុវត្តបានឡើយ ។

ទី២. បណ្តឹងទាស់ បានបង្កើតឱ្យមាននូវគោលការណ៍អវិភាគ។ មានន័យថា ទោះបីជា ភាគីដែលបានធ្វើនូវបណ្តឹងទាស់នោះ បានប្តឹងទាស់តែផ្នែកណាមួយ នៃសាលក្រមកំបាំងមុខក៏ដោយ ក៏អានុភាពនៃការផ្អាកការចូលជាស្ថាពរនៃសាលក្រមកំបាំងមុខ មានគ្រប់ផ្នែកទាំងអស់នៃសាលក្រមកំបាំងមុខ។

# ជំពូកទី២. ចំណាត់ការលើនីតិវិធីនៃបណ្តឹងទាស់

នៅពេលភាគីដែលតុលាការចេញនូវសាលក្រមកំបាំងមុខ មានបំណងធ្វើបណ្តឹងទាស់ ភាគីត្រូវដាក់ពាក្យបណ្តឹងទៅតុលាការ ដើម្បីឱ្យតុលាការ ធ្វើចំណាត់ការលើពាក្យបណ្តឹងទៅតាមនីតិវិធីដែលច្បាប់បានកំណត់ ។ ចំណាត់ការទាំងនោះមានទៅតាមដំណាក់កាលដូចជា ៖ ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង (២.១) ការដកពាក្យបណ្តឹង និង ការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់ (២.២) ការសម្រេចសេចក្តីលើបណ្តឹងទាស់ (២.៣) និង សាលក្រមកំបាំងមុខលើកទី២ (២.៤) ។

## ២.១. ដំណាក់កាលនៃការដាក់ពាក្យបណ្តឹង

ដើម្បីឱ្យបណ្តឹងទាស់មានអានុភាព ភាគីត្រូវដាក់ពាក្យបណ្តឹងទាស់ ទៅតុលាការដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹង និង សមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹង ។

### ២.១.១. សមត្ថកិច្ចរបស់តុលាការ

#### ២.១.១.១. សមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹង

តុលាការមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹង គឺជាតុលាការ ដែលបានចេញនូវសាលក្រមកំបាំងមុខ[៣១] (តុលាការសាមី) ។

សមត្ថកិច្ចនេះ ជាសមត្ថកិច្ចផ្តាច់មុខ ។ មានន័យថាមានតែតុលាការ ដែលបានចេញសាលក្រមកំបាំងមុខនោះទេ ដែលមានសមត្ថកិច្ចក្នុងការទទួលពាក្យបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខ ។ ដូចនេះ ក្រៅពីតុលាការដែលបានចេញនូវសាលក្រមកំបាំងមុខ មិនមានសមត្ថកិច្ចក្នុងការទទួលនូវពាក្យបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខនោះឡើយ ។

#### ២.១.១.២. សមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹង

តុលាការនៃបណ្តឹងទាស់ គឺជាតុលាការដែលមានសមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹងទាស់ ។ បន្ទាប់ពីទទួលពាក្យបណ្តឹងទាស់រួចមកតុលាការនៃបណ្តឹងទាស់ ដែលជាតុលាការមានសមត្ថកិច្ចក្នុងការពិនិត្យពាក្យបណ្តឹងទាស់ ត្រូវពិនិត្យអំពីភាពត្រឹមត្រូវនៃទម្រង់ដែលច្បាប់បានកំណត់មានដូចជា[៣២]៖

[៣១] មាត្រា ២០៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[៣២] មាត្រា ២០៥ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

-សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្តឹងទាស់ ។

-បំណងនៃការប្តឹងទាស់ចំពោះសាលក្រមកំបាំងមុខ ។

-មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ។

ប្រសិនបើពាក្យបណ្តឹងទាស់ មិនស្របតាមចំណុចណាមួយ ដែលបានរៀបរាប់ខាងលើនេះទេ តុលាការនឹងធ្វើការបង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្តឹង ដោយកំណត់អំឡុងពេលសមរម្យសម្រាប់ធ្វើការកែតម្រូវនូវចំណុចដែលបានខ្វះខាតនោះ ។

ក្នុងករណី ដែលភាគីទទួលបានកំណត់អំឡុងពេល សម្រាប់ធ្វើការកែតម្រូវនូវចំណុចខ្វះខាតហើយ តែភាគីដែលធ្វើបណ្តឹងទាស់មិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការនឹងលើកបណ្តឹងទាស់នោះចោលដោយដីកាសម្រេច ។ ដីកាសម្រេចលើកបណ្តឹងចោលនេះ អាចប្តឹងជំទាស់បាន[៣៣] ក្នុងរយៈពេល ១ សប្តាហ៍បន្ទាប់ពីបានទទួលដំណឹងអំពីដីការសម្រេចលើកចោលបណ្តឹងទាស់[៣៤] ។ ប៉ុន្តែប្រសិនបើពាក្យបណ្តឹងទាស់ស្របតាមទម្រង់ដែលមានកំណត់ក្នុងបញ្ញត្តិមាត្រា ២០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឬ ពាក្យបណ្តឹងទាស់ត្រូវបានភាគីកែតម្រូវតាមការបង្គាប់តុលាការនោះ បណ្តឹងទាស់នឹងកើតមានឡើងនូវអានុភាព ។

### ២.១.២. អានុភាពនៃពាក្យបណ្តឹងទាស់

បន្ទាប់ពីមានការទទួលស្គាល់អំពីភាពត្រឹមត្រូវលើទម្រង់នៃបណ្តឹងទាស់ អំឡុងពេលធ្វើបណ្តឹងទាស់ និង មូលហេតុជាមូលដ្ឋានក្នុងការធ្វើបណ្តឹងទាស់រួចមក បណ្តឹងទាស់នឹងមានអានុភាព ។ នៅពេលដែលពាក្យបណ្តឹងទាស់មានអានុភាព នីតិវិធីនៃបណ្តឹងត្រូវត្រឡប់ទៅសភាពដើមវិញ ដោយត្រូវចាប់ផ្តើមត្រឹមពេលដែលអវត្តមានរបស់ភាគីកើតមានឡើង[៣៥] ។

ដូច្នេះតុលាការត្រូវកំណត់កាលបរិច្ឆេទថ្មី ដើម្បីចាប់ផ្តើមអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដើម្បីចាប់ផ្តើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ[៣៦] ។

---

[៣៣] មាត្រា ២០៦ កថាខណ្ឌទី១,២,៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៤] មាត្រា ៣០៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៥] មាត្រា ២០៨ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៦] មាត្រា ២០៨ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

មានន័យថា ប្រសិនបើតុលាការបានចេញសាលក្រមកំបាំងមុខភាគីណាមួយ ដោយហេតុថា អវត្តមានចាប់តាំងនីតិវិធីត្រៀមសម្រាប់ទាញហេតុផល រហូតដល់នីតិវិធីទាញហេតុដោយផ្ទាល់មាត់ បណ្ដឹងទាស់ត្រូវបានធ្វើឡើង នីតិវិធីត្រូវចាប់ផ្ដើមសារឡើងវិញ ចាប់ពីនីតិវិធីត្រៀមសម្រាប់ទាញហេតុផល ។ ក៏ប៉ុន្តែ ប្រសិនបើភាគីទើបតែអវត្តមាននាកាលបរិច្ឆេទទាញហេតុផលដោយផ្ទាល់មាត់ នីតិវិធីត្រូវចាប់ជាថ្មីចាប់ពីនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់តែប៉ុណ្ណោះ ។ បន្ទាប់ពីពាក្យបណ្ដឹងទាស់មានអានុភាពដែលត្រូវបានទទួលស្គាល់ តុលាការត្រូវចាប់ផ្ដើមអនុវត្តនីតិវិធីនៃបណ្ដឹងទាស់នោះ ដោយតុលាការត្រូវបញ្ជូនពាក្យបណ្ដឹងទាស់ទៅភាគីម្ខាងទៀត ហើយកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យបណ្ដឹងទាស់ និង ធ្វើការកោះហៅគូភាគី[៣៧] ។

## ២.២. ការដកពាក្យបណ្ដឹង និង ការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្ដឹងទាស់

នៅពេលមានបណ្ដឹងទាស់ ដែលបានធ្វើឡើងដោយភាគី ដែលតុលាការបានចេញនូវសាលក្រមកំបាំងមុខ ក្នុងគោលបំណងដើម្បីឱ្យតុលាការមានការផ្លាស់ប្ដូរ ឬ លុបចោលសេចក្ដីសម្រេចដើម ។ បន្ទាប់ពីពិនិត្យពាក្យបណ្ដឹង ថាមានភាពត្រឹមត្រូវរួចហើយ តុលាការត្រូវកំណត់ការបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យ និង កោះហៅគូភាគី ។ ទន្ទឹមនឹងនេះផងដែរភាគីដែលបានធ្វើនូវបណ្ដឹងទាស់ក៏មានសិទ្ធិក្នុងការដកពាក្យបណ្ដឹងរបស់ខ្លួនវិញ ចាប់ពីពេលដែលបានដាក់ពាក្យបណ្ដឹងរហូតដល់សាលក្រម នៃបណ្ដឹងទាស់ត្រូវបានប្រកាស ។ ដើម្បីឱ្យកាន់តែច្បាស់ទៅលើចំណុចដែលបានធ្វើការរៀបរាប់ខាងលើ និង ត្រូវធ្វើការបកស្រាយលម្អិតនៅក្នុងចំណុចខាងក្រោមជាបន្តបន្ទាប់៖

### ២.២.១. ការដកពាក្យបណ្ដឹងទាស់

ការដកពាក្យបណ្ដឹងទាស់ គឺអាចធ្វើបានរហូតដល់ពេល ដែលសាលក្រមចុងក្រោយរបស់តុលាការនៃបណ្ដឹងទាស់ ត្រូវបានប្រកាស[៣៨] ។ ចំពោះនីតិវិធីនៃការដកពាក្យបណ្ដឹងទាស់ ត្រូវបានអនុវត្តដូចគ្នាទៅ និង ការដកពាក្យបណ្ដឹងឧទ្ធរណ៍[៣៩] ដែលការដកពាក្យបណ្ដឹងទាស់ត្រូវបានធ្វើការបែងចែកជា ២ (ពីរ) ប្រភេទ៖

#### ២.២.១.១. ការដកពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរ

នៅពេលដែលមាន ការដកពាក្យបណ្ដឹងជាលាយល័ក្ខណ៍អក្សរ តុលាការត្រូវធ្វើការបញ្ជូន

---

[៣៧] មាត្រា ២០៦ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៨] មាត្រា ២១២ កថាខណ្ឌទី១ និង២៦៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៣៩] មាត្រា ២១២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

លិខិតដកពាក្យបណ្ដឹងទៅចុងចម្លើយ[40] ។ ប្រសិនបើចុងចម្លើយមិនបានតវ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីបានទទួលការបញ្ជូនលិខិត ស្ដីពីការដកពាក្យបណ្ដឹងនោះទេ ត្រូវបានចាត់ទុកថា ចុងចម្លើយបានយល់ព្រមពីការដកពាក្យបណ្ដឹង[41] ។

#### ២.២.១.២. ការដកពាក្យបណ្ដឹងដោយផ្ទាល់មាត់

នៅពេលដែលមានការដកពាក្យបណ្ដឹងដោយផ្ទាល់មាត់ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវធ្វើការបញ្ជូនឯកសារចម្លងកំណត់ហេតុនៃកាលបរិច្ឆេទក្នុងនីតិវិធីនោះ ទៅចុងចម្លើយក្នុងករណីដែលចុងចម្លើយអវត្តមាន ។ ច្បាប់បានទុកសិទ្ធិឱ្យចុងចម្លើយធ្វើការតវ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីទទួលបានការបញ្ជូនឯកសារចម្លងកំណត់ហេតុនៃកាលបរិច្ឆេទក្នុងនីតិវិធីនោះ ប្រសិនបើចុងចម្លើយមិនបានធ្វើការតវ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីទទួលបានការបញ្ជូនឯកសារចម្លងកំណត់ហេតុនៃកាលបរិច្ឆេទក្នុងនីតិវិធីនោះទេ ត្រូវបានចាត់ទុកថា ចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្ដឹង[42] ។

ប្រសិនបើ ការដកពាក្យបណ្ដឹងដោយផ្ទាល់មាត់ត្រូវបានធ្វើឡើង នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ចុងចម្លើយមានវត្តមាននៅក្នុងកាលបរិច្ឆេទនោះ តុលាការមិនចាំបាច់ធ្វើការចម្លងឯកសារកំណត់ហេតុនៃកាលបរិច្ឆេទក្នុងនីតិវិធីនោះទេ ព្រោះចុងចម្លើយបានដឹងពីការដកពាក្យនោះហើយ[43] ។ ច្បាប់បានទុកសិទ្ធិឱ្យចុងចម្លើយធ្វើការតវ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីថ្ងៃដែលមានការដកពាក្យបណ្ដឹង ប្រសិនបើចុងចម្លើយមិនបានធ្វើតវ៉ា ក្នុងអំឡុងពេល ២ (ពីរ) សប្ដាហ៍ បន្ទាប់ពីថ្ងៃដែលមានការដកពាក្យបណ្ដឹងនោះទេ ត្រូវចាត់ទុកថា ចុងចម្លើយបានយល់ព្រមនឹងការដកពាក្យបណ្ដឹងនោះហើយ[44] ។

### ២.២.២. ការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យលើបណ្ដឹងទាស់

ចំពោះការកំណត់កាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យបណ្ដឹងទាស់ ត្រូវកំណត់ក្នុងអំឡុងពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីថ្ងៃដែលពាក្យបណ្ដឹងទាស់ត្រូវបានដាក់ទៅតុលាការ លើកលែងតែក្នុងករណីដែលមានមូលហេតុពិសេស ។ បន្ទាប់ពីតុលាការបានកំណត់អំពីកាលបរិច្ឆេទថ្មីក្នុងការវិនិច្ឆ័យ

[40] មាត្រា ២១៧ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[41] មាត្រា ២១៧ កថាខណ្ឌទី៥ វាក្យខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[42] មាត្រា ២១៧ កថាខណ្ឌទី៥ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[43] មាត្រា ២១៧ កថាខណ្ឌទី៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[44] មាត្រា ២១៧ កថាខណ្ឌទី៥ វាក្យខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

បណ្តឹងទាស់រួច តុលាការត្រូវធ្វើការកោះហៅគូភាគី ។ នីតិវិធីនៃការកោះហៅគូភាគី និងត្រូវធ្វើការបកស្រាយនៅចំណុចបន្ទាប់ ។

### ២.២.៣. ការកោះហៅគូភាគី

ការកោះហៅគូភាគី ជានីតិវិធីមួយដែលប្រើសម្រាប់ជូនដំណឹងទៅភាគី ដែលមានការពាក់ព័ន្ធ នឹងផលប្រយោជន៍ ។ នីតិវិធីនៃការកោះហៅទៅភាគី តម្រូវឱ្យធ្វើការបញ្ជូន ទើបជានីតិវិធីមួយត្រឹមត្រូវតាមបញ្ញត្តិច្បាប់ដែលបានកំណត់ ។

ចំពោះការបញ្ជូន គឺជាការជូនដំណឹងដែលធ្វើឡើងតាមវិធីដែលច្បាប់បានកំណត់ ដើម្បីជូនដំណឹង អំពីខ្លឹមសារនៃឯកសារតាមផ្លូវបណ្តឹងចំពោះភាគី និង អ្នកដ៏ទៃទៀតដែលមានការពាក់ព័ន្ធនឹងផលប្រយោជន៍ ។ ចំពោះវិធីនៃការបញ្ជូន ត្រូវបានធ្វើការបែងចែកជា ៦ (ប្រាំមួយ) ប្រភេទរួមមាន៖ ការបញ្ជូនដោយការប្រគល់ ការបញ្ជូនដោយការជួបប្រទះ ការបញ្ជូនដោយបង្គ្រប់កិច្ច ការបញ្ជូនដោយទុកចោល ការបញ្ជូនទៅបរទេស និង ការបញ្ជូនដោយការផ្សាយជាសាធារណៈ ។

#### ២.២.៣.១. ការបញ្ជូនដោយការប្រគល់

ជាការបញ្ជូនត្រូវធ្វើឡើង ដោយការប្រគល់នូវឯកសារទៅឱ្យជន ដែលត្រូវទទួលការបញ្ជូន[៥] ។ ការបញ្ជូនត្រូវធ្វើទៅលំនៅដ្ឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់របស់ជនដែលត្រូវទទួលការបញ្ជូន ។ម្យ៉ាងវិញទៀតការបញ្ជូនក៏អាចធ្វើទៅអ្នកតំណាង ដែលច្បាប់បានកំណត់ អាចធ្វើទៅទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់អ្នកតំណាងនោះបាន[៦]។

#### ២.២.៣.២. ការបញ្ជូនដោយការជួបប្រទះ

ការបញ្ជូនដោយជួបប្រទះ ត្រូវបានធ្វើឡើងក្នុងករណីពុំច្បាស់ថា ជនដែលត្រូវទទួលការបញ្ជូនមានលំនៅដ្ឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម និង ទីស្នាក់នៅក្នុងប្រទេសកម្ពុជាទេ ការបញ្ជូនអាចធ្វើបាននៅកន្លែង ដែលបានជួបប្រទះនោះបាន លើកលែងតែមានករណីដែលមានភាគីបានជូនដំណឹងពី ទីកន្លែង សម្រាប់ធ្វើការបញ្ជូន តាមបញ្ញាត្តិមាត្រា ២៥០ កថាខណ្ឌទី១ (ការជូនដំណឹងអំពីកន្លែងបញ្ជូនជាអាទិ៍) នៃក្រមនីតិវិធីរដ្ឋប្បវេណី ត្រូវបញ្ជូនទៅទីកន្លែងដែលភាគីបានជូនដំណឹងនោះ។ ម្យ៉ាងវិញទៀតទោះបីជាជនដែលត្រូវទទួលការបញ្ជូនមានលំនៅដ្ឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម និង ទីស្នាក់ការនៅក្នុងប្រទេសកម្ពុជាច្បាស់លាស់ និង មានការជូនដំណឹងពីទីកន្លែងដែល

---

[៥] មាត្រា ២៤៧ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៦] មាត្រា ២៤៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ត្រូវបញ្ជូនក៏ដោយ បើភាគីមិនប្រកែកចំពោះការបញ្ជូននៅកន្លែងដែលជួបប្រទះទេ គឺអាចធ្វើការបញ្ជូនដោយការជួបប្រទះបាន[៤៧] ។

**២.២.៣.៣. ការបញ្ជូនដោយបង្គ្រប់កិច្ច**

ការបញ្ជូនដោយបង្គ្រប់កិច្ច ដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនធ្វើការបញ្ជូន ទៅតាមទីកន្លែងដែលត្រូវបញ្ជូន តែពុំបានជួបជនដែលត្រូវទទួលការបញ្ជូននៅទីកន្លែងដែលត្រូវបញ្ជូននោះទេ មន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនអាចប្រគល់ឯកសារ ដែលត្រូវបញ្ជូននោះទៅឱ្យអ្នកបម្រើ ឬ អ្នកផ្សេងទៀតដែលធ្វើការនៅទីនោះ ឬ អ្នកនៅជាមួយ ដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសារនោះបាន[៤៨] ។

ចំពោះអ្នកដែលមានការយល់ដឹងសមរម្យក្នុងការទទួលឯកសាររួមមាន៖

-អ្នកដែលយល់ច្បាស់អំពីសារៈសំខាន់នៃការបញ្ជូន

-យល់ដឹងពីអត្ថន័យនៃឯកសារដែលបានទទួល

-មានសមត្ថភាពអាចយកឯកសារនោះ ទៅប្រគល់ឱ្យជនដែលត្រូវទទួលការបញ្ជូន ។

**២.២.៣.៤. ការបញ្ជូនដោយទុកចោល**

ការបញ្ជូនដោយទុកចោល គឺជាវិធីការបញ្ជូនមួយដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនធ្វើការបញ្ជូនទៅតាមទីកន្លែងដែលត្រូវបញ្ជូន តែជនដែលត្រូវទទួលការបញ្ជូន ឬ អ្នកដែលត្រូវទទួលការប្រគល់ឯកសារតាមរយៈការបញ្ជូនដោយបង្គ្រប់កិច្ច មិនព្រមទទួលការបញ្ជូនដោយគ្មានមូលហេតុត្រឹមត្រូវ ដូច្នេះឯកសារដែលត្រូវធ្វើការបញ្ជូននោះអាចទុកចោលនៅកន្លែងដែលត្រូវបញ្ជូននោះបាន[៤៩] ។ ប៉ុន្តែប្រសិនបើការបដិសេធមិនព្រមទទួលការបញ្ជូន ដោយមាននូវមូលហេតុត្រឹមត្រូវច្បាស់លាស់ ឯកសារដែលត្រូវធ្វើការបញ្ជូនមិនអាចទុកចោលបានទេ ។

**២.២.៣.៥. ការបញ្ជូនទៅបរទេស**

ការបញ្ជូនទៅបរទេសធ្វើឡើងក្នុងករណី ជនដែលត្រូវទទួលការបញ្ជូន មានទីលំនៅនៅបរទេស ហើយពុំមានទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការដែលអាចធ្វើការបញ្ជូនបាននៅ

---

[៤៧] មាត្រា ២៥១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤៨] មាត្រា ២៥២ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៤៩] មាត្រា ២៥២ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ក្នុងព្រះរាជាណាចក្រកម្ពុជាទេ ការបញ្ជូនទៅជនដែលត្រូវទទួលការបញ្ជូន អាចធ្វើតាមរបៀបចំនួន ២ (ពីរ)[៥០] ៖

- ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិបរទេស គប្បីបញ្ជូនដោយប្រគល់ឱ្យក្រសួង ឬ ស្ថាប័នដែលមាននៃប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន ។

- ករណីជនដែលត្រូវទទួលការបញ្ជូនជាជនជាតិខ្មែរតែរស់នៅបរទេស គប្បីបញ្ជូនដោយប្រគល់ឱ្យឯកអគ្គរាជទូត ភារធារី ឬ កុងស៊ុល របស់ប្រទេសកម្ពុជាប្រចាំប្រទេសនោះជាអ្នកអនុវត្តការបញ្ជូន ។

មុននឹងបញ្ជូន តុលាការគប្បីពិនិត្យមើល អនុសញ្ញា ឬ សន្ធិសញ្ញារវាងប្រទេសនោះជាមួយ និង ប្រទេសកម្ពុជា ឬ កិច្ចព្រមព្រៀងផ្សេងទៀត ឬ ការជួយគ្នាទៅវិញទៅមកផ្នែកច្បាប់ ព្រោះករណីខ្លះក្នុងបទដ្ឋានគតិយុត្តទាំងនេះមានកំណត់ពីរបៀបនៃការបញ្ជូន ។ ចំពោះការបញ្ជូនទៅជនជាតិបរទេស ដែលរស់នៅក្នុងព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវប្រើតាមវិធីនៃការបញ្ជូនដូចជាការបញ្ជូនចំពោះជនជាតិខ្មែរផងដែរ ។

### ២.២.៣.៦. ការបញ្ជូនតាមការផ្សាយជាសាធារណៈ

ការបញ្ជូនតាមការផ្សាយជាសាធារណៈ ត្រូវបានធ្វើឡើងនៅពេល ដែលមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនបានធ្វើការបញ្ជូនស្ទើរតែគ្រប់វិធីនៃការបញ្ជូនទាំងអស់ នៅតែមិនអាចទទួលបានលទ្ធផល ទើបការបញ្ជូនត្រូវបានធ្វើតាមរយៈការផ្សាយជាសាធារណៈ ដែលវិធីនេះជាវិធីចុងក្រោយក្នុងការបញ្ជូន ។ ការបញ្ជូនតាមការផ្សាយជាសាធារណៈត្រូវមាន លក្ខខ័ណ្ឌ របៀបបញ្ជូនជាសាធារណៈនឹង អានុភាព ដែលតម្រូវឱ្យមានទើបអាចជ្រើសរើសវីធីការផ្សាយ ជាសាធារណៈ យកមកធ្វើការបញ្ជូនបាន ។ ចំពោះការបញ្ជូនតាមការផ្សាយជាសាធារណៈ ដើម្បីធ្វើការបញ្ជូនឱ្យមានភាពត្រឹមត្រូវតាមនីតិវិធីត្រូវគោរពនូវលក្ខខ័ណ្ឌមួយចំនួនៈ

-ទោះបីជាមានការខិតខំប្រឹងប្រែងស្រាវជ្រាវយ៉ាងណាក៏ដោយ ក៏មិនអាចដឹងពីទីកន្លែងដែលត្រូវបញ្ជូន ។

-បើ យើងដឹងពីទីកន្លែងដែលត្រូវបញ្ជូន ប៉ុន្តែ ការបញ្ជូនមិនអាចធ្វើបាន ទោះបីជាយើងបានព្យាយាមបញ្ជូនតាមរបៀបនៃការបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោលក៏ដោយ ។

-ករណី មិនអាចធ្វើការបញ្ជូនទៅបរទេស ដោយការប្រគល់កិច្ចការបញ្ជូន ។

---

[៥០] មាត្រា ២៥៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

-ករណីតុលាការ មិនបានទទួលលិខិតបញ្ជាក់ ពីការបញ្ជូនពីក្រសួង ឬ ស្ថាប័ន ដែលមានសមត្ថកិច្ចនៅបរទេសក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែគិតចាប់ពីពេលបញ្ជូន ។

ឱ្យតែមានល័ក្ខខ័ណ្ឌណាមួយ ក្នុងចំណោមល័ក្ខខ័ណ្ឌដែលបានរៀបរាប់ខាងលើ គឺអាចធ្វើការបញ្ជូន តាមការផ្សព្វផ្សាយជាសាធារណៈបាន ។ ទន្ទឹមនឹងការគោរពតាមល័ក្ខខ័ណ្ឌ ដែលបានរៀបរាប់ខាងលើ ទើបអាចធ្វើការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈបាន ក៏ប៉ុន្តែនៅមានល័ក្ខខ័ណ្ឌមួយទៀត ដែលតម្រូវឱ្យមានពាក្យសុំរបស់ភាគី សុំឱ្យតុលាការធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ និង បន្ទាប់ពីទទួលបានការអនុញ្ញាតពីតុលាការ តាមបញ្ញាត្តិមាត្រា២៥៥ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ទើបធ្វើការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈបាន ។ ប៉ុន្តែដើម្បីជៀសវាងនូវការយឺតយ៉ាវ តុលាការក៏អាចបង្គាប់ឱ្យក្រឡាបញ្ជីធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ដោយឆន្ទានុសិទ្ធិទោះជាគ្មានពាក្យសុំរបស់ភាគីក៏ដោយ ក្នុងករណីដែលតុលាការយល់ឃើញថា មានការចាំបាច់ តាមបញ្ញត្តិមាត្រា២៥៥ កថាខណ្ឌទី១ និងកថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ម្យ៉ាងវិញទៀត បើការបញ្ជូនតាមការផ្សព្វផ្សាយជាសាធារណៈត្រូវបានធ្វើឡើង ក្នុងករណីដែលល័ក្ខខ័ណ្ឌនៃការដោយបញ្ជូនបង្គ្រប់កិច្ច និង ការបញ្ជូនដោយទុកចោលត្រូវបានបំពេញហើយ តែនៅតែមិនអាចបញ្ជូនបាន នោះក្រឡាបញ្ជី គប្បីជូនដំណឹងដោយរបៀបសមរម្យ (តាមទូរស័ព្ទ ផ្ញើរតាមប៉ុស្តិ៍ប្រៃសនីយ៍ ឬ បិទនៅលំនៅដ្ឋាន ទីសំណាក់ របស់អ្នកដែលត្រូវទទួលការបញ្ជូនជាដើម) អំពីហេតុដែលនាំឱ្យធ្វើការបញ្ជូនជាសាធារណៈទៅភាគី ដែលត្រូវទទួលការបញ្ជូននោះ ។ ការបញ្ជូនតាមការផ្សាយជាសាធារណៈចាប់ពី២ (ពីរ) លើកឡើងទៅ ចំពោះភាគីដដែល តុលាការត្រូវធ្វើដោយឆន្ទានុសិទ្ធិ ប៉ុន្តែចំពោះករណីការបញ្ជូនទៅជន ដែលនៅបរទេសត្រូវតែមាន ពាក្យសុំរបស់ភាគីរាល់លើកនៃការផ្សាយជាសាធារណៈ ។ មាត្រា ២៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦ បានចែងអំពីរបៀបបញ្ជូនជាសាធារណៈដែលក្នុងនោះរួមមាន ៖

-ក្រឡាបញ្ជី ត្រូវបិទប្រកាសនៅកន្លែងសម្រាប់បិទប្រកាស របស់តុលាការ ឬ កន្លែងដែលតុលាការទទួលស្គាល់ថាសមស្រប (អាចប៉ុស្តិ៍ សាលាឃុំ...ជាដើម) និង ត្រូវប្រកាសថា ក្រឡាបញ្ជីជាអ្នករក្សាទុកនៅឯកសារដែលធ្វើការបញ្ជូន ហើយឯកសារនេះនឹងអាច ប្រគល់ឱ្យជន ដែលត្រូវទទួលការបញ្ជូននៅពេលណាក៏បាន ។

-តុលាការអាចចុះក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ផ្សាយថាបានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈ ។

-ការបញ្ជូនដែលត្រូវធ្វើទៅបរទេស ក្រឡាបញ្ជីតុលាការអាចជូនដំណឹងថា បានធ្វើការបញ្ជូនតាមការផ្សាយជាសាធារណៈហើយ ជំនួសការប្រកាសផ្សាយនៅក្នុងរាជកិច្ច ឬ ក្នុងសារព័ត៌មាន ។

បន្ទាប់ពីតុលាការបានកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យ និង បានកោះហៅគូភាគី រួចរាល់ហើយ តុលាការត្រូវរងចាំកាលបរិច្ឆេទដែលបានកំណត់នោះមកដល់ ដើម្បីធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីលើបណ្តឹងទាស់នោះ ។ កាលបរិច្ឆេទដែលបានកំណត់មកដល់ តុលាការធ្វើការវិនិច្ឆ័យ និង ការសម្រេចសេចក្តីលើបណ្តឹងទាស់នោះ ដោយការស្រាវជ្រាវលើមូលហេតុនៃបណ្តឹងទាស់ ដោយឆន្ទានុសិទ្ធិរបស់តុលាការ និង ចេញនូវសាលក្រមសម្រេចលើបណ្តឹងទាស់ ។

## ២.៣. ការសម្រេចសេចក្តីលើបណ្តឹងទាស់

បន្ទាប់ពីតុលាការបានកំណត់កាលបរិច្ឆេទក្នុងការវិនិច្ឆ័យលើបណ្តឹងទាស់ និង បានធ្វើការកោះហៅគូភាគីរួចមក តុលាការអាចធ្វើការស្រាវជ្រាវលើមូលហេតុនៃបណ្តឹងទាស់ដោយឆន្ទានុសិទ្ធិ និង ធ្វើការសម្រេចសេចក្តីលើបណ្តឹងទាស់ ។ ចំណុចទាំងនេះ នឹងត្រូវលើកយកមកបកស្រាយនៅចំណុចបន្ទាប់ ។

### ២.៣.១. ការស្រាវជ្រាវលើមូលហេតុនៃបណ្តឹងទាស់ដោយឆន្ទានុសិទ្ធិរបស់តុលាការ

មុននឹងវិនិច្ឆ័យ និង ធ្វើការសម្រេចសេចក្តីលើបណ្តឹងទាស់ តុលាការអាចធ្វើការស្រាវជ្រាវដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីភាពត្រឹមត្រូវនៃពាក្យបណ្តឹងទាស់តាមទម្រង់ និង អំឡុងពេលដែលច្បាប់បានកំណត់ និង អំពីភាពត្រឹមត្រូវនៃមូលហេតុបណ្តឹងទាស់[៥១] ។ បន្ទាប់ពីតុលាការធ្វើការស្រាវជ្រាវរួចប្រសិនបើយល់ឃើញថា ពាក្យបណ្តឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ចំពោះទម្រង់ ឬ អំឡុងពេលនៃការធ្វើបណ្តឹងទាស់ តុលាការនឹងចេញនូវដីកាសម្រេចលើកចោលនូវបណ្តឹងទាស់។ ម៉្យាងទៀត ប្រសិនបើតុលាការយល់ឃើញថា ពាក្យបណ្តឹងទាស់គ្មានមូលហេតុត្រឹមត្រូវ តុលាការនឹងចេញនូវដីកាសម្រេចច្រានចោលបណ្តឹងទាស់ ។

ផ្ទុយទៅវិញ ប្រសិនបើតុលាការយល់ឃើញថា ពាក្យបណ្តឹងទាស់មានភាពត្រឹមត្រូវតាមទម្រង់ ធ្វើឡើងក្នុងអំឡុងពេលដែលច្បាប់បានកំណត់ និង មាននូវមូលហេតុត្រឹមត្រូវដែលជាមូលដ្ឋានគ្រឹះក្នុងការធ្វើបណ្តឹងទាស់ តុលាការនឹងធ្វើការវិនិច្ឆ័យ និង សម្រេចសេចក្តីលើបណ្តឹងទាស់ ដោយចេញនូវសាលក្រមសម្រេចលើបណ្តឹងទាស់ ។

បន្ទាប់ពីតុលាការបានធ្វើនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចមក តុលាការអាចធ្វើការប្រកាសសាលក្រមភ្លាមៗ ក្រោយពីបញ្ចប់នីតិវិធី ឬ លើកពេលសម្រាប់ការប្រកាសសាលក្រម

[៥១] មាត្រា ២០៧ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ដោយការកំណត់អំឡុងពេលមិនឱ្យលើសពី ១ (មួយ) ខែ គិតចាប់ពីថ្ងៃដែលបានបញ្ចប់នូវនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ។ ក្នុងអំឡុងពេលដែលមិនទាន់បានប្រកាសសាលក្រមលើបណ្តឹងទាស់ ភាគីដើមអាចធ្វើការដកពាក្យបណ្តឹងបាន រហូតដល់ពេលសាលក្រមលើបណ្តឹងទាស់ត្រូវបានប្រកាស ។

### ២.៣.២. សាលក្រមសម្រេចលើបណ្តឹងទាស់

សាលក្រមសម្រេចលើបណ្តឹងទាស់ ដែលចេញដោយតុលាការ បន្ទាប់ពីយល់ឃើញថា បណ្តឹងទាស់មានភាពត្រឹមត្រូវតាមទម្រង់ អំឡុងពេលសម្រាប់ធ្វើបណ្តឹងទាស់ត្រឹមត្រូវតាមច្បាប់ដែលបានកំណត់ និង មានមូលហេតុត្រឹមត្រូវ តុលាការមានសមត្ថកិច្ចលើបណ្តឹងទាស់ធ្វើការសម្រេចសេចក្តីដោយចេញនូវសាលក្រម ២ (ពីរ) ប្រភេទ៖

-សាលក្រមសម្រេចលើបណ្តឹងទាស់ ដោយតម្កល់សាលក្រមកំបាំងមុខទុកជាបានការ[៥២] ។ សាលក្រមសម្រេចលើបណ្តឹងទាស់ ដោយតម្កល់សាលក្រមកំបាំងមុខទុកជាបានការ ជាសាលក្រមដែលតុលាការសម្រេច ដោយផ្អែកលើការជំនុំជម្រះជាថ្មីម្តងទៀត បន្ទាប់ពីបានចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ ហើយទទួលបានលទ្ធផលដូចគ្នាទៅនឹងសាលក្រមកំបាំងមុខដែរ ។

-សាលក្រមដែលសម្រេចលើបណ្តឹងទាស់[៥៣] ។ សាលក្រមសម្រេចលើបណ្តឹងទាស់ ជាសាលក្រមដែលតុលាការសម្រេចដោយផ្អែកលើការជំនុំជម្រះជាថ្មីម្តងទៀត បន្ទាប់ពីចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ ហើយទទួលបាននូវលទ្ធផលមិនដូចគ្នាទៅនឹងសាលក្រមកំបាំងមុខឡើយ ។

## ២.៤. សាលក្រមកំបាំងមុខលើកទី២

តុលាការត្រូវចេញនូវសាសក្រមកំបាំងមុខជាលើកទី២ ប្រសិនបើភាគីដែលបានធ្វើនូវបណ្តឹងទាស់មិនបានចូលបង្ហាញខ្លួនតាមការកំណត់របស់តុលាការ ។ មូលហេតុដែលនាំឱ្យតុលាការចេញនូវសាលក្រមកំបាំងមុខលើកទី២ ដោយសារភាគីដែលបានធ្វើបណ្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលចាប់ផ្តើមអនុវត្តនិតិវិធីឡើងវិញទេ ដោយសារមូលហេតុនេះតុលាការនឹងសម្រេចច្រានចោលបណ្តឹងទាស់ ដោយចេញនូវសាលក្រមកំបាំងមុខម្តងទៀត[៥៤] ។ សាលក្រមកំបាំងមុខម្តងទៀត គេហៅសាលក្រមកំបាំងមុខលើកទី២ ។ ទន្ទឹមនឹងការចេញសាលក្រមកំបាំងមុខលើកទី២ ក៏មានមូលហេតុមួយចំនួន ដែលតុលាការមានសមត្ថកិច្ចលើបណ្តឹងទាស់ មិនអាច

[៥២] មាត្រា ២០៩ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[៥៣] មាត្រា ២០៩ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦
[៥៤] មាត្រា ២១១ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

ចេញនូវសាលក្រមកំបាំងមុខជាលើកទី២បានផងដែរ ។ ចំពោះមូលហេតុទាំងនោះនឹងត្រូវបានលើកយកមកធ្វើការបកស្រាយនូវក្នុងចំណុចខាងក្រោម ៖

### ២.៣.១. មូលហេតុដែលមិនអាចចេញនូវសាលក្រមកំបាំងមុខលើកទី២

នៅពេលភាគីដែលបានធ្វើបណ្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលចាប់ផ្តើមអនុវត្តនិតិវិធីឡើងវិញក៏ដោយ ក៏តុលាការមិនអាចសម្រេចច្រានចោលបណ្តឹងទាស់ដោយចេញនូវសាលក្រមកំបាំងលើកទី២ បានទេ[៥៥] ។ ប្រសិនបើ ករណី ៖

-ភាគីដែលមិនបានបង្ហាញខ្លួន ដោយសារមិនបានទទួលការកោះហៅស្របច្បាប់ ។

-ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបាន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន ។

-បណ្តឹងមិនស្របច្បាប់ ។

-ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយ មុនកាលបរិច្ឆេទនោះ ។

ចំពោះមូលហេតុដែលមិនអាចចេញសាលក្រមកំបាំងមុខលើកទី២ ដែលបានរៀបរាប់ខាងលើនឹងត្រូវបានធ្វើការបកស្រាយលម្អិតនៅក្នុងចំណុចខាងក្រោម៖

#### ២.៣.១.១. ភាគីដែលមិនបានបង្ហាញខ្លួន ដោយសារមិនបានទទួលការកោះហៅស្របច្បាប់

ប្រសិនបើភាគីទទួលបានការកោះហៅ តែមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទ នោះតុលាការនឹងអាចចេញនូវសាលក្រមកំបាំងមុខ ។ ផ្ទុយទៅវិញ ដោយសារតែមិនបានទទួលការកោះហៅស្របច្បាប់ ទើបភាគីមិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទនោះ ការចេញនូវសាលក្រមកំបាំងមុខមិនត្រូវបានអនុញ្ញាតឡើយ ។ ភាគីមិនបានបង្ហាញខ្លួន ដោយសារមិនបានទទួលការកោះហៅស្របច្បាប់ អាចមានស្ថានភាពដូចខាងក្រោម៖

**ក. ករណីមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន និង មន្ត្រីដែលប្រតិបត្តិការបញ្ជូនមិនបានបញ្ជូនដីកាកោះទៅដល់ភាគី**

មន្ត្រីដែលទទួលបន្ទុកកិច្ចការបញ្ជូន និង មន្ត្រីដែលប្រតិបត្តិការបញ្ជូនមិនបានធ្វើការបញ្ជូនដីកាកោះទៅដល់ភាគី ដោយសារតែមន្ត្រីទទួលបន្ទុកកិច្ចការបញ្ជូន រៀបចំដីកាកោះមានភាព

[៥៥] មាត្រា ២០២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

យឺតយ៉ាវ ឬ ដោយសារមន្ត្រីដែលប្រតិបត្តិការបញ្ជូនមិនបានធ្វើការបញ្ជូនទៅបុគ្គលដែលត្រូវទទួលការបញ្ជូនដោយរកមិនឃើញនូវអាសយដ្ឋាន ឬ បុគ្គលដែលត្រូវទទួលការបញ្ជូន បញ្ហាទាំងអស់នេះ ហើយដែលជាហេតុនាំឱ្យភាគីមិនបានបង្ហាញខ្លួន ដោយសារមិនបានទទួលការកោះហៅ ដោយស្របច្បាប់ ។

**ខ. ករណីដែលការកោះហៅត្រូវបានបញ្ជូនដោយមន្ត្រី ឬ បុគ្គលដែលគ្មានសមត្ថកិច្ចក្នុងការប្រតិបត្តិការបញ្ជូន**

ការទទួលបានការកោះហៅមិនស្របច្បាប់ដោយសារ មន្ត្រី ឬ បុគ្គលដែលប្រតិបត្តិការបញ្ជូនមិនមែនជាមន្ត្រី ឬ បុគ្គលដែលច្បាប់បានកំណត់ ។ ចំពោះមន្ត្រីទទួលបន្ទុកប្រតិបត្តិការបញ្ជូនដែលច្បាប់បានកំណត់រួមមាន ៖ ក្រឡាបញ្ជី អាជ្ញាសាលា និង បុគ្គលិកប្រៃសនីយ៍ ដោយយោងតាមបញ្ញត្តិមាត្រា២៤៦ កថាខណ្ឌទី៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។ បុគ្គលផ្សេងពីបុគ្គលដែលបានរៀបរាប់នេះមិនមានសមត្ថកិច្ចក្នុងការប្រតិបត្តិការបញ្ជូនឡើយ ។ មូលហេតុដែលនាំឱ្យដីកាកោះ ដែលបញ្ជូនទៅភាគីមិនស្របច្បាប់អាចបណ្តាលមកពីការបញ្ជូនត្រូវបានធ្វើឡើងដោយបុគ្គល ឬ មន្ត្រីដែលគ្មានសមត្ថកិច្ចក្នុងការប្រតិបត្តិការបញ្ជូន ដោយការបញ្ជូនដីកាកោះទៅភាគី ត្រូវបានធ្វើឡើងតាមរយៈ មេឃុំ ចៅសង្កាត់ នគរបាល កងរាជអាវុធហត្ថ ជាអាទិ៍ ។

**គ. ករណីបុគ្គលទទួលការបញ្ជូន ជាបុគ្គលដែលគ្មានសមត្ថភាពក្នុងការទទួលការបញ្ជូន**

ការបញ្ជូនដីកាកោះដោយមិនស្របច្បាប់ ដោយសារបុគ្គលដែលទទួលការបញ្ជូន ជាបុគ្គលដែលគ្មានសមត្ថភាពក្នុងការទទួលការបញ្ជូន ដែលបុគ្គលទាំងនោះរួមមាន ៖ បុគ្គលដែលអសមត្ថភាពក្នុងការធ្វើបណ្តឹង អនីតិជន ជននៅក្រោមអាណាព្យាបាលទូទៅ និង ជននៅក្រោមហិតូបត្ថម្ភ បុគ្គលទាំងនេះ គឺជាបុគ្គលដែលមិនមានការយល់ដឹង ឬ មិនមានការយល់ដឹងគ្រប់គ្រាន់ក្នុងការទទួលការបញ្ជូនដីកាកោះនោះទេ ។ នៅពេលដែលបុគ្គលដែលអសមត្ថភាពក្នុងការធ្វើបណ្តឹងដែលបានរៀបរាប់ខាងលើទទួលដីកាកោះពីមន្ត្រីប្រតិបត្តិការបញ្ជូន បុគ្គលទាំងនោះមិនបានយល់ដឹងពីអត្ថន័យនៃដីកាកោះ និង មិនបានប្រាប់ទៅភាគីដែលត្រូវទទួលការបញ្ជូន នូវខ្លឹមសារនៃដីកាកោះនោះទេ នាំឱ្យភាគីដែលត្រូវទទួលការបញ្ជូនមិនបានទទួលដំណឹងពីដីកាកោះ និង ខ្លឹមសារនៃដីកាកោះ ជាហេតុនាំឱ្យដីកាកោះដែលបានបញ្ជូននោះ មានភាពមិនស្របច្បាប់។

បន្ទាប់ពីបានធ្វើការបកស្រាយអំពីមូលហេតុដែលភាគីមិនបានបង្ហាញខ្លួន ដោយសារមិនបានទទួលការកោះហៅដោយស្របច្បាប់រួចមក តុលាការមិនអាចចេញសាលក្រមកំបាំងមុខលើកទី២ទេ ព្រោះនេះមិនមែនជាកំហុសរបស់ភាគីនោះទេ ដូច្នេះតុលាការត្រូវពន្យាកាលបរិច្ឆេទ នៃនីតិវិធី។

**២.៣.១.២. ភាគីដែលមិនបានបង្ហាញខ្លួន ដោយមានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបាន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬកាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន**

ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបាន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន ក្នុងករណីនេះភាគីដែលត្រូវទទួលដីកាកោះ បានទទួលការបញ្ជូនដីកាកោះដោយស្របច្បាប់ ។ ប៉ុន្តែភាគីមិនអាចបង្ហាញខ្លួនបាន ដោយសារមានគ្រោះមហន្តរាយធម្មជាតិ (ទឹកជំនន់ រញ្ជួយដី ជាអាទិ៍) ឬ ក៏ភាគីគាត់មានធុរៈមិនអាចជៀសវាងបាន ជាហេតុនាំឱ្យភាគីមិនអាចបង្ហាញខ្លួនបាន ឬ ហេតុការណ៍ផ្សេងទៀតដែលមិនអាចជៀសវាងបាន ដែលវាកើតឡើងក្រៅឆន្ទៈរបស់ភាគី ។ ចំពោះហេតុការណ៍ដែលបានរៀបរាប់ខាងលើ ជាហេតុការណ៍ដែលមិនអាចជៀសវាងបាន ដូច្នេះតុលាការមិនអាចចេញនូវសាលក្រមកំបាំងមុខជាលើកទី២ បានឡើយ ។

**២.៣.១.៣. បណ្ដឹងមិនស្របច្បាប់**

បណ្ដឹងមិនស្របច្បាប់ គឺជាបណ្ដឹងដែលធ្វើឡើង ៖

-ទៅកាន់តុលាការដែលគ្មានសមត្ថកិច្ចផ្ដាច់មុខ ក្នុងការទទួលបណ្ដឹងទាស់ មានន័យថាតុលាការដែលមានសមត្ថកិច្ចផ្ដាច់មុខ ក្នុងការទទួលបណ្ដឹងទាស់ គឺជាតុលាការដែលបានចេញសាលក្រមកំបាំងមុខ ។

-ដោយភាគីដែលធ្វើបណ្ដឹងអសមត្ថភាពក្នុងការធ្វើបណ្ដឹង

-ដោយខ្វះសិទ្ធិតំណាងចំពោះភាគីដែលអសមត្ថភាពក្នុងការធ្វើបណ្ដឹង

-ដោយមិនគោរពតាមល័ក្ខខ័ណ្ឌដែលបានបញ្ញត្តិក្នុងមាត្រា ២០៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី ។

ចំណុចដែលបានរៀបរាប់ខាងលើនេះហើយ ដែលជាមូលហេតុនាំឱ្យបណ្ដឹងដែលបានធ្វើឡើងមិនស្របច្បាប់ ។ នៅពេលដែលមានបណ្ដឹងមិនស្របច្បាប់កើតមានឡើងតុលាការមិនអាចធ្វើការសម្រេចសេចក្ដីដោយចេញសាលក្រមកំបាំងមុខជាលើកទី២ បាននោះទេ ។

**២.៣.១.៤. ខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្ដីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះ**

ក្នុងករណីខ្លឹមសារនៃសេចក្ដីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្ដីថ្លែងការណ៍

នោះមិនបានជូនដំណឹងទៅចុងចម្លើយមុនកាលបរិច្ឆេទនោះ តុលាការមិនអាចចេញសាលក្រម កំបាំងមុខជាលើកទី២ ចំពោះភាគីចុងម្លើយបានទេ ។ នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់ ភាគីដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ ដោយអវត្តមានភាគីចុងចម្លើយ ហើយសេចក្តីថ្លែងការណ៍ របស់ដើមចោទដែលបានធ្វើឡើង ក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នោះ មិនបានធ្វើការ បញ្ជូនទៅភាគីចុងចម្លើយមុនកាលបរិច្ឆេទ នៃការប្រកាសសាលក្រមនោះទេ នេះហើយជាហេតុធ្វើឱ្យ តុលាការ មិនអាចចេញនូវសាលក្រមកំបាំងមុខជាលើកទី២បាន ព្រោះភាគីចុងចម្លើយ មិនបានដឹងពី ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដែលដើមចោទបានធ្វើក្នុងនីតិវិធីទាញហេតុផលផ្ទាល់មាត់នោះទេ ។ ម៉្យាងវិញទៀតប្រសិនបើសេចក្តីថ្លែងការណ៍ដែលដើមចោទបានថ្លែង ត្រូវបានចុងចម្លើយបានធ្វើវិវាទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃនីតិវិធីទាញហេតុផល ដោយផ្ទាល់មាត់ម្តងរួចហើយ តុលាការក៏មិនអាចចេញនូវសាលក្រមកំបាំងមុខជាលើកទី២ បានដែរ ។

ចំពោះមូលហេតុដែលតុលាការមិនអាចចេញសាលក្រមកំបាំងមុខលើកទី២ ទាំង ០៤ (បួន) ចំណុច ដែលបានបកស្រាយខាងលើ ដោយសារតែមូលហេតុមិនបានបង្ហាញខ្លួនបានមិនមែនជា កំហុសរបស់ភាគី ជាមូលហេតុដែលមិនអាចជៀសវាងបានក្រៅឆន្ទៈរបស់ភាគី ជាពិសេសទៀតនោះ ដោយសារតែក្នុងក្រមនីតិវិធីរដ្ឋប្បវេណី គោរពនូវគោលការណ៍ចំពោះមុខ ដោយបានកំណត់ថាតុលាការ មិនអាចជំនុំជម្រះដោយមិនបានធ្វើការសាកសួរ ឬ ទទួលបានការកោះហៅបានឡើយ ។ ទោះបីជាក្នុង ករណីណាក៏ដោយ តុលាការត្រូវគោរពនូវគោលការណ៍ចំពោះមុខ[៥៦] ។

## ២.៣.២. ការហាមឃាត់ធ្វើបណ្តឹងទាស់ចំពោះសាលក្រមកំបាំងមុខលើកទី២

ក្រោយពីតុលាការ បានចេញនូវសាលក្រមកំបាំងមុខលើកទី២ ដោយសារតែភាគីដែលបាន ធ្វើបណ្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូង បន្ទាប់ពីការចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញ នោះដោយគ្មានមូលហេតុ ដែលអាចឱ្យតុលាការជឿបានថា ការដែលមិនបានបង្ហាញខ្លួននៅ កាលបរិច្ឆេទដំបូងនោះ ព្រោះការមិនទទួលបានការកោះហៅស្របច្បាប់ គ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀត ឬ ការមិនទទួលបាន ខ្លឹមសារនៃសេចក្តីថ្លែងការណ៍របស់ដើមចោទ នៃ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ភាគីដែលត្រូវបានតុលាការចេញនូវសាលក្រម កំបាំងមុខជាលើកទី២ មិនអាចធ្វើបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខលើកទី២ នោះបានទៀត ទេ[៥៧] ។

[៥៦] មាត្រា ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

[៥៧] មាត្រា ២១១ កថាខណ្ឌទី ២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានធ្វើការស្រាវជ្រាវលើប្រធានបទ " បណ្តឹងទាស់ក្នុងនីតិវិធីរដ្ឋប្បវេណី " រួចមក យើងខ្ញុំអាចសន្និដ្ឋានបានថា ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានគោរពនូវគោលការណ៍ចំពោះមុខ និង សិទ្ធិក្នុងការពឹងពាក់តុលាការក្នុងការដោះស្រាយវិវាទរដ្ឋប្បវេណី ។ ស្របទៅនឹងគោលការណ៍ចំពោះមុខ និង សិទ្ធិក្នុងការពឹងពាក់តុលាការក្នុងការដោះស្រាយវិវាទរដ្ឋប្បវេណី ទើបក្រមនីតិវិធីរដ្ឋប្បវេណីបានបញ្ញត្តិស្តីពី បណ្តឹងទាស់ ដែលអាចធ្វើឡើងប្រឆាំងទៅនឹងសាលក្រមកំបាំងមុខនឹងបានបើកសិទ្ធិដល់ភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ មានលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិទាមទារឱ្យតុលាការ ឬ ចៅក្រមដែលបានចេញសាលក្រមកំបាំងមុខធ្វើការសម្រេចសេចក្តីម្តងទៀត ។ ម៉្យាងវិញទៀត បណ្តឹងទាស់ ជាបណ្តឹងមួយដែលមានសារៈសំខាន់ក្នុងការពារផលប្រយោជន៍របស់ភាគី ដែលត្រូវតុលាការបានចេញសាលក្រមកំបាំងមុខ ព្រោះពេលដែលតុលាការចេញនូវសាលក្រមកំបាំងមុខ មានន័យថាភាគីអវត្តមានមិនបានចូលរួម មិនបានទទួលការសាកសួរ និង បានធ្វើឱ្យភាគីបាត់បង់នូវសិទ្ធិរបស់គាត់ ។ ដោយឃើញបញ្ហានេះទើបក្រមនីតិវិធីរដ្ឋប្បវេណី បានបញ្ញត្តិ បណ្តឹងទាស់ឡើង ក្នុងគោលបំណងឱ្យភាគីបានបង្ហាញនូវសិទ្ធិ និង ដាក់មធ្យោបាយតទល់ទៅឱ្យអស់ពីលទ្ធភាពដែលខ្លួនមាន ដើម្បីស្វែងរកយុត្តិធម៌ ដល់គូភាគីចំពោះវិវាទរដ្ឋប្បវេណី និង បានបើកសិទ្ធិឱ្យភាគី ដែលត្រូវបានតុលាការចេញសាលក្រមកំបាំងមុខ អាចធ្វើបណ្តឹងទាស់ ចំពោះសាលក្រមកំបាំងមុខទៅកាន់តុលាការ ដែលបានចេញសាលក្រមកំបាំងមុខដើម្បីទាមទារឱ្យតុលាការ ឬ ចៅក្រមដែលបានសម្រេចសេចក្តីធ្វើការលុបចោល ឬ ផ្លាស់ប្តូរនូវសេចក្តីសម្រេចដើមបាន ។

សរុបសេចក្តីមក បទប្បញ្ញត្តិពាក់ព័ន្ធនឹង បណ្តឹងទាស់ ដែលមានចែងក្នុងក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៦ គឺមានភាពល្អប្រសើរ និង ជាកត្តាមួយដ៏សំខាន់ក្នុងការរួមចំណែកស្វែករកយុត្តិធម៌ជូនភាគី និង បានផ្តល់នូវសិទ្ធិ ដល់ភាគីអវត្តមានដោយមិនមានមូលហេតុច្បាស់លាស់ ដែលត្រូវបានតុលាការចេញសាលក្រមកំបាំងមុខនោះ មានសិទ្ធិក្នុងការធ្វើបណ្តឹងទាស់ ដើម្បីបង្ហាញនូវសិទ្ធិ និង ដាក់មធ្យោបាយក្នុងការតទល់ឱ្យអស់ពីលទ្ធភាព ។ នៅពេលដែលភាគីបានប្រើប្រាស់សិទ្ធិរបស់ខ្លួនរួចហើយ ភាគីនឹងព្រមទទួលយកនូវសេចក្តីសម្រេចរបស់តុលាការ ។ ដូច្នេះ អាចនិយាយបានថា បណ្តឹងទាស់ ជាបណ្តឹងមួយដ៏មានសារៈសំខាន់ចំពោះភាគី ដែលត្រូវបានតុលាការចេញនូវសាលក្រមកំបាំងមុខ អាចមានលទ្ធភាពក្នុងការប្រើប្រាស់សិទ្ធិរបស់គាត់ម្តងទៀត ក្នុងនីតិវិធីបណ្តឹងទាស់ និង ផ្តល់ឪកាសដល់តុលាការក្នុងការស្វែងរកការពិតជូនភាគី ។

# ឯកសារយោង

## បទដ្ឋានគតិយុត្ត

១- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

២- ក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៦ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧០៦/០២១ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦

៣- ក្រមរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧ លេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ២០០៧

## ឯកសារផ្សេងៗ

៤- សេចក្តីពន្យល់នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ភាគ ១ ស្តីពីនីតិវិធីបណ្តឹង ឆ្នាំ ២០០៨

៥- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី របស់ក្រសួងយុត្តិធម៌ ឆ្នាំ២០០៧

៦- មេរៀន នីតិវិធីរដ្ឋប្បវេណី របស់លោកសាស្ត្រាចារ្យ កេត សុជាតិ ឆ្នាំ២០១៥

៧- មេរៀន បណ្តឹងឧបាស្រ័យ របស់លោក សេង នាង ចៅក្រមតុលាការកំពូល

៨- មេរៀន នីតិវិធីនៃការបញ្ជូន របស់លោក ហេង សុខណា ចៅក្រមសាលាដំបូងរាជធានីភ្នំពេញ

៩- វចនានុក្រមនៃសម្តេចសង្ឃរាជ ជួន ណាត ព.ស ២៥១១ គ.ស ១៩៦៧

# ក្រមនីតិវិធីរដ្ឋប្បវេណី

# នៃ

# ព្រះរាជាណាចក្រកម្ពុជា

# ព្រះរាជក្រម

នស/រកម/០៧០៦/០២១

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ២៦ ខែ ឧសភា ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី ៤ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងដោយគ្មានកែប្រែអ្វីឡើយ កាលពីថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ ២០០៦នាសម័យប្រជុំពេញអង្គលើកទី១នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ដីកាដែលផ្លាស់ប្តូរសាលក្រមសម្រេចអង្គសេចក្តីនៅពេលក្រោយ ។

**មាត្រា ១៩៨.–** វិសាលភាពបុគ្គលដែលត្រូវទទួលអានុភាពរបស់សាលក្រមស្ថាពរ

សាលក្រមស្ថាពរមានអានុភាពចំពោះបុគ្គលដែលបានកំណត់ដូចខាងក្រោមនេះ :

ក-ភាគី ។

ខ-តតិយជន ក្នុងករណីដែលភាគីធ្វើជាដើមចោទ ឬ ចុងចម្លើយនៃបណ្តឹងជំនួសតតិយជននោះ ។

គ-បុគ្គលដែលទទួលបន្តនូវសិទ្ធិ ឬ កាតព្វកិច្ច ពីអ្នកដែលបានកំណត់ក្នុងចំណុចទាំងពីរខាងលើនេះ ក្រោយពីបណ្តឹងត្រូវបានចាត់ការ ។

ឃ-បុគ្គលដែលកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃការទាមទារ សម្រាប់ផលប្រយោជន៍របស់បុគ្គលដែលបានកំណត់ក្នុងចំណុចទាំងបីខាងលើនេះ ។

**មាត្រា ១៩៩.–** អានុភាពនៃសាលក្រមស្ថាពររបស់តុលាការបរទេស

សាលក្រមស្ថាពររបស់តុលាការបរទេស ត្រូវមានអានុភាព លុះត្រាតែបានបំពេញល័ក្ខខ័ណ្ឌទាំងអស់ ដូចខាងក្រោមនេះ :

ក-បើសិទ្ធិជម្រះក្តីរបស់តុលាការបរទេសត្រូវបានទទួលស្គាល់ ដោយច្បាប់ ឬ សន្ធិសញ្ញា ឬ អនុសញ្ញា ដែលព្រះរាជាណាចក្រកម្ពុជាជាភាគី ។

ខ-បើចុងចម្លើយដែលចាញ់ក្តី បានទទួលការបញ្ជូនដីកាកោះហៅ ឬ ដីកាបង្គាប់ដែលចាំបាច់ដើម្បីចាប់ផ្តើមនីតិវិធី ឬ មិនបានទទួលទេ តែបានឆ្លើយដោះសាតបចំពោះបណ្តឹងនោះ ។

គ-បើខ្លឹមសារនៃសាលក្រម និង នីតិវិធីនៃបណ្តឹងនោះ មិនប៉ះពាល់សណ្តាប់ធ្នាប់សាធារណៈ ឬ ទំនៀមទម្លាប់ល្អនៃព្រះរាជាណាចក្រកម្ពុជា ។

ឃ-បើមានការធានាទៅវិញទៅមករវាងព្រះរាជាណាចក្រកម្ពុជា និង បរទេស ។

## ផ្នែកទី ៥

## សាលក្រមកំបាំងមុខ

**មាត្រា ២០០.–** សាលក្រមកំបាំងមុខដើមចោទ

១-បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ ។

២-បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទដើម្បីបន្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការអាចបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់បាន ។

៣-បើដើមចោទមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ទេ តុលាការត្រូវច្រានចោលការទាមទាររបស់ដើមចោទនោះ ដោយសាលក្រមកំបាំងមុខ ។

**មាត្រា ២០១.–** សាលក្រមកំបាំងមុខចុងចម្លើយ

១-បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទលើកទី ១ នៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលទេ តុលាការត្រូវបញ្ឈប់នីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ដោយភ្លាមៗ ហើយកំណត់នូវកាលបរិច្ឆេទលើកទី ១ នៃការទាញហេតុផលដោយផ្ទាល់មាត់ ។

២-បើចុងចម្លើយមិនបានបង្ហាញខ្លួន នៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ តុលាការត្រូវចាត់ទុកថា ចុងចម្លើយបានសារភាពតាមសេចក្តីថ្លែងការណ៍របស់ដើមចោទដែលទាក់ទងនឹងអង្គហេតុ ហើយបើយល់ឃើញថា ការទាមទាររបស់ដើមចោទត្រឹមត្រូវ តុលាការត្រូវទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយសាលក្រមកំបាំងមុខ តែបើយល់ឃើញថា ការទាមទាររបស់ដើមចោទមិនត្រឹមត្រូវទេ តុលាការត្រូវច្រានចោលការទាមទារនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលចុងចម្លើយធ្វើវិវាទលើការអះអាងរបស់ដើមចោទ នៅកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ពីមុនមក ។

**មាត្រា ២០២.–** ករណីដែលមិនអាចចេញសាលក្រមកំបាំងមុខ

បើមានករណីណាមួយដូចខាងក្រោមនេះ តុលាការមិនអាចចេញសាលក្រមកំបាំងមុខ បានឡើយ :

ក-ភាគីដែលមិនបានបង្ហាញខ្លួន មិនបានទទួលការកោះហៅស្របច្បាប់ ។

ខ-ភាគីដែលមិនបានបង្ហាញខ្លួន មានមូលហេតុដែលអាចទទួលស្គាល់ថា ពិតជាមិនអាចបង្ហាញខ្លួនបានមែន ដោយសារគ្រោះមហន្តរាយធម្មជាតិ ឬ កាលៈទេសៈផ្សេងទៀតដែលមិនអាចជៀសវាងបាន ។

គ-បណ្តឹងមិនស្របច្បាប់ ។

ឃ-ខ្លឹមសារនៃសេចក្តីថ្លែងការណ៍ ដែលដើមចោទបានធ្វើនៅកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ដែលចុងចម្លើយមិនបានបង្ហាញខ្លួន ហើយខ្លឹមសារនៃសេចក្តីថ្លែងការណ៍នោះមិនបានជូនដំណឹងទៅចុងចម្លើយ មុនកាលបរិច្ឆេទនោះ ។

**មាត្រា ២០៣.–** ការពន្យារកាលបរិច្ឆេទ

១-បើយល់ឃើញថា អំឡុងពេលនៃការកោះហៅមានរយៈពេលខ្លីពេក ឬ យល់ឃើញថា ភាគីមិនអាចមកបង្ហាញខ្លួនបានដោយគ្មានកំហុសទេ តុលាការអាចពន្យារកាលបរិច្ឆេទនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់បាន ។

២-បើតុលាការ បានពន្យារកាលបរិច្ឆេទតាមកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវធ្វើការកោះហៅភាគីដែលមិនបានបង្ហាញខ្លួននោះ តាមកាលបរិច្ឆេទថ្មី ។

**មាត្រា ២០៤.–** បណ្តឹងទាស់

១-បើភាគីមិនបានបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ដោយសារមានហេតុដែលមិនអាចព្យាករបាន ឬ ហេតុដែលមិនអាចជៀសវាងបាន ហើយបានទទួលសាលក្រមកំបាំងមុខ ភាគីនោះអាចប្តឹងទាស់ចំពោះសាលក្រមនោះបាន ។

២-បណ្តឹងទាស់ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ត្រូវធ្វើឡើងក្នុងអំឡុងពេល ២ (ពីរ) សប្តាហ៍ ដោយគិតចាប់ពីថ្ងៃដែលបានទទួលការបញ្ជូនសាលក្រមកំបាំងមុខនោះ ។ អំឡុងពេលនេះពុំអាចពន្យារបានឡើយ ។

៣-បើសាលក្រមកំបាំងមុខ ត្រូវបានបញ្ជូនតាមរយៈការបិទប្រកាសជាសាធារណៈ ឬ តាមរយៈការបញ្ជូននៅបរទេស តុលាការត្រូវកំណត់អំឡុងពេលដែលអាចប្តឹងទាស់ នៅក្នុងសាលក្រមកំបាំងមុខនោះ ។

**មាត្រា ២០៥.—** របៀបប្ដឹងទាស់

១-ការប្ដឹងទាស់ត្រូវធ្វើឡើងដោយដាក់ពាក្យបណ្ដឹងទាស់ទៅតុលាការដែលបានចេញសាលក្រមកំបាំងមុខ ។

២-នៅក្នុងពាក្យបណ្ដឹងទាស់ ត្រូវសរសេរចំណុចដូចខាងក្រោម :

ក-ឈ្មោះ ឬ នាមករណ៍ និង អាសយដ្ឋានរបស់គូភាគី ហើយនិង ឈ្មោះ និង អាសយដ្ឋានរបស់អ្នកតំណាងដែលច្បាប់បានកំណត់ ។

ខ-សញ្ញាណសាលក្រមកំបាំងមុខដែលជាកម្មវត្ថុនៃការប្ដឹងទាស់ ។

គ-បំណងនៃការប្ដឹងទាស់ចំពោះសាលក្រមដែលបានកំណត់ក្នុងចំណុច ខ ខាងលើនេះ ។

ឃ-មូលហេតុដែលមិនអាចមកបង្ហាញខ្លួនតាមកាលបរិច្ឆេទទាន់ពេលវេលា ។

**មាត្រា ២០៦.—** ការពិនិត្យ និង ការបញ្ជូនពាក្យបណ្ដឹងទាស់

១-ក្នុងករណីដែលពាក្យបណ្ដឹងទាស់មិនស្របនឹងបញ្ញត្តិនៃមាត្រា ២០៥ (របៀបប្ដឹងទាស់) នៃក្រមនេះ តុលាការត្រូវកំណត់អំឡុងពេលសមរម្យ និង បង្គាប់ឱ្យកែតម្រូវចំណុចខ្វះខាតនៃពាក្យបណ្ដឹងនោះ ក្នុងអំឡុងពេលនោះ ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ប្រសិនបើភាគីដែលប្ដឹងទាស់មិនបានកែតម្រូវចំណុចខ្វះខាតទេ តុលាការត្រូវលើកពាក្យបណ្ដឹងទាស់នោះចោលដោយដីកាសម្រេច ។

៣-ចំពោះដីកាសម្រេចដែលបានកំណត់ក្នុងកថាខណ្ឌទី ២ ខាងលើនេះ អាចប្ដឹងជំទាស់បាន ។

៤-ក្នុងករណីដែលពាក្យបណ្ដឹងទាស់គ្មានចំណុចខ្វះខាតទេ តុលាការត្រូវបញ្ជូនពាក្យបណ្ដឹងទាស់នោះទៅភាគីម្ខាងទៀត ហើយកំណត់កាលបរិច្ឆេទថ្មីដើម្បីវិនិច្ឆ័យបណ្ដឹងទាស់នោះ និង កោះហៅគូភាគី ។

**មាត្រា ២០៧.—** ការវិនិច្ឆ័យ និង ការសម្រេចសេចក្ដីលើបណ្ដឹងទាស់

១-តុលាការត្រូវធ្វើការស្រាវជ្រាវ ដោយឆន្ទានុសិទ្ធិរបស់ខ្លួន អំពីភាពត្រឹមត្រូវនៃពាក្យបណ្ដឹងទាស់តាមទម្រង់ និង អំឡុងពេលដែលកំណត់ដោយច្បាប់ និង អំពីភាពត្រឹម

ត្រូវនៃមូលហេតុបណ្ដឹងទាស់ ។

២-តុលាការត្រូវលើកចោលនូវបណ្ដឹងទាស់ ដោយដីកាសម្រេច ប្រសិនបើយល់ឃើញថា ពាក្យបណ្ដឹងទាស់នោះមិនត្រឹមត្រូវតាមច្បាប់ តែបើយល់ឃើញថា ពាក្យបណ្ដឹងទាស់នោះ គ្មានមូលហេតុត្រឹមត្រូវទេ តុលាការត្រូវច្រានចោលបណ្ដឹងនោះដោយដីកាសម្រេច ។

**មាត្រា ២០៨.–** អានុភាពនៃបណ្ដឹងទាស់ដែលត្រូវបានទទួលស្គាល់

១-ក្នុងករណីដែលពាក្យបណ្ដឹងទាស់ត្រូវបានទទួលស្គាល់ នីតិវិធីនៃបណ្ដឹងនោះត្រូវត្រឡប់ទៅសភាពដើមវិញ ពីត្រឹមពេលអវត្តមាននោះកើតឡើង ។

២-ក្នុងករណីដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ តុលាការត្រូវកំណត់កាលបរិច្ឆេទថ្មីដើម្បីចាប់ផ្ដើមអនុវត្តនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល ឬ ដើម្បីចាប់ផ្ដើមធ្វើការទាញហេតុផលដោយផ្ទាល់មាត់ឡើងវិញ ហើយត្រូវជូនដំណឹងនេះទៅឱ្យគូភាគី ។

**មាត្រា ២០៩.–** សាលក្រមថ្មី

១-បើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញ មានលទ្ធផលដូចសាលក្រមកំបាំងមុខ នោះតុលាការត្រូវចេញសាលក្រមថ្មីដែលប្រកាសថា តម្កល់សាលក្រមកំបាំងមុខនោះទុកជាបានការ ។

២-បើសាលក្រមដែលត្រូវចេញដោយផ្អែកលើការជំនុំជម្រះជាថ្មី បន្ទាប់ពីចាប់ផ្ដើមអនុវត្តនីតិវិធីឡើងវិញ គ្មានលទ្ធផលដូចសាលក្រមកំបាំងមុខទេ នោះតុលាការត្រូវលុបចោលសាលក្រមកំបាំងមុខនោះនៅក្នុងសាលក្រមថ្មី ។

**មាត្រា ២១០.–** សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន

បើសាលក្រមកំបាំងមុខត្រូវបានធ្វើឡើងស្របតាមទម្រង់ដែលច្បាប់បានកំណត់ ទោះបីជាត្រូវលុបចោលសាលក្រមនោះ ដោយផ្អែកលើពាក្យបណ្ដឹងទាស់ក៏ដោយ ក៏សោហ៊ុយដែលកើតឡើងដោយសារអវត្តមាន ត្រូវជាបន្ទុករបស់ភាគីដែលមិនបានបង្ហាញខ្លួនដែរ លើកលែងតែករណីដែលសោហ៊ុយនោះបានកើតឡើង ដោយសារសកម្មភាពបណ្ដឹងមិនត្រឹមត្រូវរបស់ភាគីម្ខាងទៀត ។

**មាត្រា ២១១.–** សាលក្រមកំបាំងមុខលើកទី ២

១-បើភាគីដែលបានប្តឹងទាស់ មិនបានបង្ហាញខ្លួននៅកាលបរិច្ឆេទដំបូងក្រោយពេលចាប់ផ្តើមអនុវត្តនីតិវិធីឡើងវិញទេ តុលាការត្រូវច្រានចោលបណ្តឹងទាស់ ដោយសាលក្រមកំបាំងមុខម្តងទៀត លើកលែងតែក្នុងករណីដែលបានកំណត់ក្នុងមាត្រា ២០២ (ករណីដែលមិនអាចចេញសាលក្រមកំបាំងមុខ) និង កថាខណ្ឌទី ២ នៃមាត្រា ២០៣ (ការពន្យារកាលបរិច្ឆេទ) នៃក្រមនេះ ។

២-ចំពោះសាលក្រមកំបាំងមុខលើកទី ២ ដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ មិនអាចប្តឹងទាស់បានទៀតទេ ។

**មាត្រា ២១២.–** បញ្ញត្តិដែលអនុវត្តដូចគ្នា

១-បញ្ញត្តិស្តីពីការដកពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះការដកពាក្យបណ្តឹងទាស់ ។

២-បញ្ញត្តិនៃផ្នែកនេះ ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះបណ្តឹងតប ។

## ផ្នែកទី ៦

## ដីកាសម្រេច

**មាត្រា ២១៣.–** ការជូនដំណឹងអំពីដីកាសម្រេច

១-ដីកាសម្រេចនឹងមានអានុភាព លុះត្រាតែត្រូវបានជូនដំណឹងតាមវិធីដែលអាចទទួលស្គាល់ថាសមរម្យ ។

២-ក្នុងករណីចេញដីកាសម្រេចជាលាយល័ក្ខណ៍អក្សរ ចៅក្រមដែលបានចេញដីកាសម្រេច ត្រូវចុះហត្ថលេខាលើដីកាសម្រេចនោះ ។

៣-នៅពេលជូនដំណឹងអំពីដីកាសម្រេច ក្រឡាបញ្ជីត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់នូវហេតុការណ៍ និងវិធីនៃការជូនដំណឹងនោះ ដាក់នៅក្នុងសំណុំរឿង ។

**មាត្រា ២១៤.–** ការលុបចោលនូវដីកាសម្រេចទាក់ទងនឹងការដឹកនាំនីតិវិធី

ដីកាសម្រេចទាក់ទងនឹងការដឹកនាំនីតិវិធីនៃបណ្តឹង អាចលុបចោលនាពេលណាក៏បាន ។

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរដ្ឋប្បវេណីលេខ:.......................
ចុះថ្ងៃទី.........ខែ...........ឆ្នាំ.........................
សាលក្រមកំបាំងមុខលេខ.........................
ចុះថ្ងៃទី...........ខែ.............ឆ្នាំ....................

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងរាជធានីភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឱ្យប្រើ

តាមក្រឹត្រលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែកុម្ភះ ឆ្នាំ១៩៩៣

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី.........ខែ.........ឆ្នាំ.................

លើសំណុំរឿងរដ្ឋប្បវេណីលេខ.................ចុះថ្ងៃទី.............ខែ................ឆ្នាំ...........

ដោយមានសមាសភាពដូចតទៅ

ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ

លោក. លោកស្រី.......................................

លោក. លោកស្រី.......................................

លោក. លោកស្រី.......................................

តំណាងអយ្យការ

លោក. លោកស្រី.......................................

ក្រឡាបញ្ជី

លោក. លោកស្រី.......................................

រវាងដើមចោទឈ្មោះ..................ភេទ.............អាយុ...........ឆ្នាំ របររកស៊ី.................................
មានទីលំនៅសព្វថ្ងៃផ្ទះលេខ......... ផ្លូវលេខ.............. ក្រុម...........ភូមិ............ ឃុំ សង្កាត់....................
ស្រុក. ខណ្ឌ................ ខេត្ត. ក្រុង....................ប្តី. ប្រពន្ធឈ្មោះ................. មានកូន................នាក់ ។

អ្នកតំណាងដោយអាណត្តិ. ពិសេស លោក. លោកស្រី........................................................

និង ចុងចម្លើយឈ្មោះ..............................ភេទ....................អាយុ............ ឆ្នាំ របររកស៊ី............
មានទីលំនៅសព្វថ្ងៃផ្ទះលេខ......... ផ្លូវលេខ.............. ក្រុម...........ភូមិ............ ឃុំ សង្កាត់....................
ស្រុក. ខណ្ឌ................ ខេត្ត. ក្រុង....................ប្តី. ប្រពន្ធឈ្មោះ................. មានកូន............នាក់ ។

អ្នកតំណាងដោយអាណត្តិ. ពិសេស លោក. លោកស្រី..........................................................

ដែលមានកម្មវត្ថុបណ្តឹង:
..............................................................................................................................................
..............................................................................................................................................
..............................................................................................................................................
..............................................................................................................................................
..............................................................................................................................................
..............................................................................................................................................
..............................................................................................................................................
..............................................................................................................................................

## វិនិច្ឆ័យសេចក្តី

១..........................................................................................................................................
..............................................................................................................................................

២..........................................................................................................................................

៣..........................................................................................................................................

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ចូល ថ្ងៃ ១៦ ខែ ០៥ ឆ្នាំ ២០១៨ ម៉ោង ១៥ ម ២០

**<u>ពាក្យបណ្តឹងទាស់</u>**

នាងខ្ញុំឈ្មោះ                    ភេទស្រី អាយុ៥០ឆ្នាំ ជនជាតិខ្មែរ
មានទីលំនៅបច្ចុប្បន្ន ភូមិគងនយ សង្កាត់គងនយ ខណ្ឌដង្កោ រាជធានីភ្នំពេញ។
លេខទូរស័ព្ទ:

ថ្ងៃទី 16 ខែ 05 ឆ្នាំ 2018

**<u>សូមគោរពចូលមក</u>**

**<u>លោកប្រធានសាលាដំបូងរាជធានីភ្នំពេញ</u>**

**<u>កម្មវត្ថុ:</u>** សុំប្តឹងទាស់នឹងសាលក្រមរដ្ឋប្បវេណីលេខ      "ត" ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ ត្រង់សេចក្តីសំរេចបញ្ចប់ចំណុចទី១.ក,ខ,គ,ឃ។

**<u>យោង:</u>** -សំណុំរឿងរដ្ឋប្បវេណីលេខ      ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ របស់សាលាដំបូងរាជធានីភ្នំពេញ។
-សាលក្រមរដ្ឋប្បវេណីលេខ      "ត" ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ។

តបតាមកម្មវត្ថុ និង យោងខាងលើ នាងខ្ញុំសូមជំរាបជូន **លោកប្រធាន** មេត្តាជ្រាបថា ៖ កាលពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ សាលាដំបូងរាជធានីភ្នំពេញ បានចេញសាលក្រមរដ្ឋប្បវេណីលេខ ៤៣៦ "ត" ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ ដែលមានខ្លឹមសារ

១.បង្គាប់ឱ្យចុងចម្លើយឈ្មោះ                    សងប្រាក់មកឱ្យដើមចោទ
នូវចំនួនទឹកប្រាក់ជាអាទិ៍៖

ក.ប្រាក់ដើមចំនួន ៣០.០០០(សាមសិបពាន់) ដុល្លារអាមេរិក។

ខ.ការប្រាក់គិតចាប់ពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ រហូតដល់ថ្ងៃសងគ្រប់ចំនួន ក្នុងអត្រាការប្រាក់១៣.២% ក្នុង១(មួយ)ឆ្នាំ។

គ.ការប្រាក់ពិន័យគិតចាប់ពីថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៤ រហូតដល់ថ្ងៃសងគ្រប់ចំនួន (ស្មើនឹងចំនួន២ដងនៃអត្រាការប្រាក់ក្នុងការកំណត់)។

ឃ.សោហ៊ុយទំរង់ការគិតចាប់ពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៥ រហូតដល់ថ្ងៃសងគ្រប់ចំនួន ក្នុងអត្រា១%ប្រចាំឆ្នាំ។

ការសំរេចសេចក្តីរបស់សាលាដំបូងរាជធានីភ្នំពេញបែបនេះ គឺជាការបំពានលើសិទ្ធិ និងផលប្រយោជន៍របស់នាងខ្ញុំយ៉ាងអយុត្តិធម៌ជាទីបំផុត ជាហេតុនាំអោយនាងខ្ញុំមិនសុខចិត្ត និងប្តឹងទាស់ចំពោះសាលក្រមរដ្ឋប្បវេណីលេខ      "ត" ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ របស់សាលាដំបូងរាជធានីភ្នំពេញ តាមនីតិវិធីច្បាប់តែម្តង។

អាស្រ័យដូចបានជំរាបជូនខាងលើ សូម **លោកប្រធាន** មេត្តាទទួលពាក្យបណ្តឹងទាស់ របស់ខ្ញុំបាទ ដើម្បីអោយតុលាការធ្វើការជំនុំជំរះត្រង់សេចក្តីសំរេចបញ្ចាប់ចំណុចទី១.ក,ខ,គ,ឃនៃសាលក្រមខាងលើនេះ ដោយក្តីអនុគ្រោះ។

សូម **លោកប្រធាន** មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ អំពីនាងខ្ញុំ ។

ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី១៦ខែឧសភា ឆ្នាំ ២០១៨

ស្នាមមេដៃស្តាំ



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

លេខៈ ចុះថ្ងៃទី ១៦
ខែ ឧសភា ឆ្នាំ ២០១៨
សំណុំរឿង រដ្ឋប្បវេណី
លេខ. ចុះថ្ងៃទី ៣១
ខែ តុលា ឆ្នាំ ២០១៧

# សេចក្តីចម្លងបណ្តឹងដាស់

ឆ្នាំពីរពាន់ដប់ប្រាំបី ខែឧសភា ថ្ងៃទីដប់ប្រាំមួយ វេលាម៉ោងដប់ប្រាំនិងម្ភៃនាទី ។

យើង ក្រឡាបញ្ជី នៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញពាក្យបណ្តឹង ទាស់ ចុះថ្ងៃទី ១៦.០៥.២០១៨ របស់ឈ្មោះ

ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ ។

ចូលមកចំពោះមុខយើងនៅការិយាល័យក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ ហើយសុំប្តឹងទាស់ នឹងសាលក្រមរដ្ឋប្បវេណីលេខ. " ត " ក.ព.រ.វ ចុះថ្ងៃទី ០៦ ខែមេសា ឆ្នាំ២០១៨ត្រង់: ទី ១.ក.ខ.គ.ឃ នៃសេចក្តីសម្រេច ។

| អ្នកប្តឹង | ក្រឡាបញ្ជី |
|---|---|
| ហត្ថលេខាឬ ផ្តិតមេដៃ | ហត្ថលេខា |

---

| បានឃើញ | បានចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
|---|---|
| ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័កព.ស ២៥៦២ | ថ្ងៃពុធ ២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធស័ក ព.ស ២៥៦២ |
| រាជធានីភ្នំពេញ,ថ្ងៃទី១៦ ខែ ឧសភា ឆ្នាំ២០១៨ | រាជធានីភ្នំពេញ,ថ្ងៃទី ១៦ខែ ឧសភា ឆ្នាំ២០១៨ |
| ជ.ប្រធានសាលាដំបូង | ក្រឡាបញ្ជី |
| អនុប្រធាន | |

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ:........................

# ដីកាសម្រេចបង្គាប់ឱ្យកែតម្រូវពាក្យបណ្ដឹងទាស់

យើង.............................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញមាត្រា២០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ........................ចុះថ្ងៃទី..............ខែ............ឆ្នាំ............ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញសាលក្រមកំបាំងមុខលេខ............................ ចុះថ្ងៃទី....... ខែ.........ឆ្នាំ...............

បានឃើញពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី.......ខែ..........ឆ្នាំ..........របស់ឈ្មោះ...........................

## សំអាងហេតុ

-...........................................................................................................................................

-...........................................................................................................................................

-...........................................................................................................................................

## ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យឈ្មោះ........................កែតម្រូវពាក្យបណ្ដឹងទាស់ ចុះថ្ងៃទី..........ខែ...........ឆ្នាំ............ ត្រង់ចំណុច..................................................ក្នុងរយៈពេល..........................................................

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី........ខែ........ឆ្នាំ................

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងរាជធានីភ្នំពេញ**

លេខ:.........................

# ដីកាសម្រេចលើកចោលពាក្យបណ្តឹងទាស់

យើង................................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញមាត្រា២០៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ.........................ចុះថ្ងៃទី...............ខែ............ឆ្នាំ............ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញសាលក្រមកំបាំងមុខលេខ............................ ចុះថ្ងៃទី....... ខែ.........ឆ្នាំ...............

បានឃើញដីកាសម្រេចឱ្យកែតម្រូវពាក្យបណ្តឹងទាស់លេខ............ចុះថ្ងៃទី.........ខែ......ឆ្នាំ.....

បានឃើញពាក្យបណ្តឹងទាស់ ចុះថ្ងៃទី.......ខែ..........ឆ្នាំ...........របស់ឈ្មោះ...........................

## សំអាងហេតុ

-.........................................................................................................................................

-.........................................................................................................................................

-.........................................................................................................................................

## ហេតុដូច្នេះសម្រេច

លើកចោលពាក្យបណ្តឹងទាស់ ចុះថ្ងៃទី..........ខែ.........ឆ្នាំ...........របស់ឈ្មោះ.......................................

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី........ខែ........ឆ្នាំ................

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

លេខ:.........................

# ដីកាសម្រេចច្រានចោលពាក្យបណ្តឹងទាស់

យើង................................ចៅក្រម, ប្រធានក្រុមប្រឹក្សាជំនុំជម្រះ នៃសាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញមាត្រា២០៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម នស/រកម/០៧០៦/០២១ ចុះថ្ងៃទី ០៦ ខែកក្កដា ឆ្នាំ២០០៦ ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ........................ចុះថ្ងៃទី..............ខែ............ឆ្នាំ............ របស់សាលាដំបូងរាជធានីភ្នំពេញ ។

បានឃើញសាលក្រមកំបាំងមុខលេខ............................ ចុះថ្ងៃទី....... ខែ.........ឆ្នាំ..............

បានឃើញពាក្យបណ្តឹងទាស់ ចុះថ្ងៃទី.......ខែ..........ឆ្នាំ..........របស់ឈ្មោះ...........................

## សំអាងហេតុ

-......................................................................................................................................

-......................................................................................................................................

-......................................................................................................................................

## ហេតុដូច្នេះសម្រេច

ច្រានចោលបណ្តឹងទាស់ ចុះថ្ងៃទី..........ខែ.........ឆ្នាំ..........របស់ឈ្មោះ......................................

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី........ខែ........ឆ្នាំ...............

**ចៅក្រម, ក្រុមប្រឹក្សាជំនុំជម្រះ**